**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**
**Université Royale de Droit et des Science Economiques**
**Royal University of Law and Economics**

## សារណាបញ្ចប់ការសិក្សា

# អង្គហេតុចម្បង និង ការសរសេរពាក្យបណ្តឹង

ស្រាវជ្រាវពីថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៧ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៧

រៀបរៀងដោយៈ

និស្សិតឈ្មោះ លោក **ជួប សុវណ្ណរតនា**

លោក **ព្រឹង ស៊ីដេត**

សាស្ត្រាចារ្យណែនាំ

**លោក គង់ សុភ័ក្ត្រ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ១៧

ឆ្នាំចូលសិក្សា ២០១៣

ឆ្នាំសរសេរសារណា ២០១៧

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ ជួប សុវណ្ណរតនា និងខ្ញុំបាទឈ្មោះ ព្រឹង ស៊ីដេត ជានិស្សិតសិក្សានៅ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ក្រុម L4C1 ជំនាន់ទី១៧ ឆ្នាំសិក្សា២០១៣-២០១៧។

យើងខ្ញុំទាំងពីរនាក់ដែលជាកូន សូមថ្លែងអំណរគុណ និងគោរពដល់លោកអ្នកមានគុណជាពិសេស គឺ **លោកឪពុក** និង **អ្នកម្តាយ** យ៉ាងជ្រាលជ្រៅគ្មានអ្វីប្រៀបផ្ទឹម ដែលបានចិញ្ចឹមបីបាច់ថែរក្សា តាំងពីតូចរហូតដល់ធំ និងបានចំណាយទាំងថវិការ សម្ភារៈ ព្រមទាំងកម្លាំងកាយ ចិត្ត ដើម្បីផ្គត់ផ្គង់ការសិក្សារបស់កូន តាំងពីបឋមសិក្សារហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រ ដោយមិនខ្លាចការនឿយហត់ និងភាពលំបាក។ គោលបំណងតែមួយគត់របស់ពួកគាត់ គឺចង់ឃើញកូនៗមានអនាគតល្អ។ គុណូបការៈរបស់ **លោកទាំងពីរ** ទោះជាយកមាស ពេជ្យកែវកង ប្រទ្វសូរកាន មកប្រៀបផ្ទឹមក៏មិនអាចស្មើបាន ហើយក៏មិនអាចរៀបរាប់ត្រឹមអត្ថបទមួយទំព័រនេះបានដែរ។

សូមថ្លែងអំណរគុណចំពោះ **ឯកឧត្តម សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលបានអនុញ្ញាតឲ្យយើងខ្ញុំទាំងពីរនាក់ ចូលមកសិក្សា និងក្រេបជញ្ជក់ចំណេះដឹងពីសំណាក់លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យដែលពោរពេញដោយចំណេះដឹង និងបទពិសោធន៍យូរឆ្នាំ និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **លោកសាស្ត្រាចារ្យ គង់ សុភ័ក្ត្រ** ដែលបានចំណាយពេលដ៏មានតម្លៃក្នុងការជួយដឹកនាំ ពន្យល់ បង្ហាត់បង្ហាញ និងលើកទឹកចិត្តដល់យើងខ្ញុំទាំងពីរនាក់ ក្នុងដំណើរការនៃការសរសេរសារណានេះឲ្យចេញជារូបរាងឡើងដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះ។

ជាចុងបញ្ចប់យើងខ្ញុំទាំងពីរនាក់ សូមបួងសួងដល់វត្ថុសក្តិសិទ្ធដែលមាននៅក្នុងលោក និងទេវត្តាឆ្នាំថ្មី មេត្តាជួយតាមថែរក្សា **លោកឪពុក អ្នកម្តាយ** និង **សាស្ត្រាចារ្យទាំងអស់** ដែលបង្រៀននៅ **សាកវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ឲ្យជួបប្រទះតែនឹងពុទ្ធពរទាំងឡាយ ៤ ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ និងបដិភានៈ កុំបីឃ្លៀងឃ្លាតឡើយ ។

# អារម្ភកថា

ក្រោយពីបានឆ្លងកាត់ការសិក្សា និងក្រេបជញ្ជក់ចំណេះដឹងអស់រយៈពេល ៤ឆ្នាំ នៅ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច** យើងខ្ញុំបានជ្រើសរើសយកប្រធានបទស្តីអំពី "**អង្គហេតុចម្បង និងការសរសេរពាក្យបណ្តឹង**" ដើម្បីយកមកធ្វើការស្រាវជ្រាវ និងចងក្រងជាឯកសារដើម្បីបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្រ្ត ក្រោមការដឹកនាំរបស់លោកគ្រូសាស្រ្តាចារ្យ **គង់ សុភ័ក្រ្ត** ។

ការជ្រើសរើសយកប្រធានបទនេះមកធ្វើការស្រាវជ្រាវ ដោយសារតែយល់ឃើញថា ប្រធានបទនេះថ្មី ដែលមិនទាន់មានអតីតនិស្សិតរូបណាបានស្រាវជ្រាវ និងតម្កល់ទុកជាឯកសារនៅក្នុងបណ្ណាល័យសិក្សានៅឡើយទេ។ ទន្ទឹមនឹងនេះ ក៏មានអ្នកច្បាប់ ឬ អ្នកវិជ្ជាជីវៈមួយចំនួននៅមានការភាន់ច្រឡំ ឬ ស្រពិចស្រពិលទៅលើប្រធានបទនេះផងដែរ ទាក់ទងទៅលើ ប្រភេទនៃអង្គហេតុក្នុងរឿងក្តី និងទម្រង់នៃការសរសេរពាក្យបណ្តឹង ជាដើម។ ម្យ៉ាងទៀត ប្រធានបទមួយនេះ នឹងអាចជួយដល់មិត្តអ្នកអាន ឬ អ្នកស្រាវជ្រាវ ក៏ដូចជាប្រជាពលរដ្ឋមួយចំនួន ដែលជួបប្រទះនឹងបញ្ហាវិវាទក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ដោយការពឹងពាក់ឲ្យតុលាការជួយស្វែងរកនូវដំណោះស្រាយតាមរយៈពាក្យបណ្តឹងរបស់ខ្លួន។

យើងខ្ញុំទាំងពីរនាក់ពិតជាមានសេចក្តីរីករាយយ៉ាងខ្លាំង ដែលបានសរសេរសារណាទាក់ទងនឹង **អង្គហេតុចម្បង និងការសរសេរពាក្យបណ្តឹង** ដោយមានការណែនាំពីលោកគ្រូសាស្រ្តាចារ្យ ដែលលោក បានផ្តល់ជាយោបល់ ពន្យល់ណែនាំ ដើម្បីអាចសរសេរសារណាមួយនេះបានទៅដោយរលូន ដោយល្អ និងត្រឹមត្រូវ ជាពិសេស យើងខ្ញុំ បានបញ្ចប់ការសរសេរសារណាមួយនេះដោយជោគជ័យ។ ការសរសេរសារណាមួយនេះឡើង ពិតជាមានចំណុចមួយចំនួនដែលខ្វះខាត ដូចនេះ យើងខ្ញុំរង់ចាំទទួលនូវការរិះគន់ដើម្បីស្តាបនាពីសំណាក់សាស្រ្តាចារ្យ និស្សិត និងមិត្តអ្នកអានគ្រប់ស្រទាប់វណ្ណៈ ដើម្បីកែលម្អសារណាមួយនេះឲ្យកាន់តែមានភាពល្អប្រសើរដែលអាចទទួលយកបាន។

យើងខ្ញុំសង្ឃឹមថា សារណាមួយនេះនឹងក្លាយជាឯកសារស្រាវជ្រាវដ៏សំខាន់ដល់មិត្តនិស្សិតគ្រប់ជំនាន់ និងមិត្តអ្នកអានគ្រប់ស្រទាប់វណ្ណៈ ដើម្បីយកវាទៅអនុវត្តនៅក្នុងវិជ្ជាជីវៈ និងជីវភាពរស់នៅប្រចាំថ្ងៃ ដែលកំពុងជួបនឹងបញ្ហាវិវាទនានា ដែលឈានទៅដល់ការពឹងពាក់តុលាការដើម្បីជួយស្វែងរកដំណោះស្រាយតាមផ្លូវច្បាប់។

# មាតិកា

ទំព័រ


**សេចក្តីផ្តើម** ........................................ ១

**ជំពូកទី១**

**បណ្តឹង**

**ផ្នែកទី១. ទម្រង់នៃពាក្យបណ្តឹង** ........................................ ៣

១.១.ចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្តឹង ........................................ ៤

១.១.១. អត្តសញ្ញាណរបស់គូភាគី ........................................ ៤

១.១.២. ខ្លឹមសារនៃសាលក្រមដែលទាមទារឲ្យតុលាការចេញ ........................................ ៥

១.១.៣. អង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ ........................................ ៥

១.២. ចំណុចដែលគួគប្បីសរសេរក្នុងពាក្យបណ្តឹង ........................................ ៦

១.២.១. អង្គហេតុដែលជាមូលហេតុនៃការទាមទារ ........................................ ៦

១.២.២.អង្គហេតុសំខាន់ៗដែលទាក់ទងនឹងអង្គហេតុដែលជាមូលហេតុនៃការទាមទារ (អង្គហេតុប្រយោល) ........................................ ៧

១.២.៣. ភស្តុតាង ........................................ ៨

**ផ្នែកទី២. ប្រភេទនៃបណ្តឹង** ........................................ ១២

២.១. បណ្តឹងទាមទារឲ្យផ្តល់ការកាលិក ........................................ ១២

២.១.១. បណ្តឹងទាមទារឲ្យផ្តល់តាវកាលិកនាពេលបច្ចុប្បន្ន ........................................ ១២

២.១.២. បណ្តឹងទាមទារឲ្យផ្តល់តាវកាលិកនាពេលអនាគត ........................................ ១៤

២.១.៣. សាលក្រមនៃបណ្តឹងទាមទារឲ្យផ្តល់តាវកាលិក ........................................ ១៦

២.២. បណ្តឹងទាមទារឲ្យបញ្ជាក់ ........................................ ១៧

២.២.១. កម្មវត្ថុនៃបណ្តឹងទាមទារឲ្យបញ្ជាក់ ........................................ ១៧

២.២.២. សាលក្រមនៃបណ្តឹងទាមទារឲ្យបញ្ជាក់ ........................................ ១៩

៣.៣. បណ្តឹងទាមទារឲ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត ........................................ ១៩

៣.៣.១. កម្មវត្ថុនៃបណ្តឹងទាមទារឲ្យបង្កើត ប្តូរ ឬ រំលត់នូវទំនាក់ទំនងគតិយុត្ត ........................................ ២០

៣.៣.២. សាលក្រមនៃបណ្តឹងទាមទារឲ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត ........................................ ២២

## ជំពូកទី២

## អង្គហេតុដែលជាមូលហេតុនៃការទាមទារ ឬ អង្គហេតុចម្បង

**ផ្នែកទី១. ទ្រឹស្តី និង ការបែងចែកអង្គហេតុចម្បង**........................................២២

១.១. អង្គហេតុនៃការកកើតឡើងនូវសិទ្ធិ........................................២៣

១.២. អង្គហេតុរារាំងសិទ្ធិ........................................២៣

១.៣. អង្គហេតុរំលត់សិទ្ធិ........................................២៣

១.៤. អង្គហេតុទប់ស្កាត់ (បដិសេធ) សិទ្ធិ........................................២៤

**ផ្នែកទី២. លំហូរនៃការបញ្ជាក់អង្គហេតុ**........................................២៤

២.២. ការទាមទារ........................................២៤

២.២.១. គោលគំនិតនៃការទាមទារ........................................២៤

២.២.២. កម្មវត្ថុនៃបណ្តឹង........................................២៥

២.២.៣. មូលហេតុនៃការទាមទារ........................................២៥

២.៣. ការអះអាង........................................២៨

២.៣.១. គោលគំនិតនៃការអះអាង........................................២៨

២.៣.២. មូលហេតុដែលអនុញ្ញាតឲ្យធ្វើការអះអាង........................................២៨

២.៣.៣. ដំណាក់កាលនៃការអះអាង........................................២៩

២.៤. ការបញ្ជាក់ (ភស្តុតាង និង អង្គហេតុ)........................................៣០

២.៤.១. អត្ថន័យ និង ភាពចាំបាច់ក្នុងការទទួលខុសត្រូវក្នុងការបញ្ជាក់ ...... ៣០

២.៤.២. វិធីបញ្ជាក់ភស្តុតាងនៃអង្គហេតុ........................................៣០

២.៤.៣. ការបែងចែកការទទួលខុសត្រូវក្នុងការបញ្ជាក់ ........................................៣១

**សេចក្តីសន្និដ្ឋាន**........................................៣២

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

បុគ្គលគ្រប់រូបទាំងអស់ ដែលរស់នៅក្នុងសង្គមតែងតែមានផ្សាភ្ជាប់នូវទំនាក់ទំនងរវាងគ្នានឹងគ្នាតាមរយៈទំនាក់ទំនងការងារ ការធ្វើពាណិជ្ជកម្ម និងទំនាក់ទំនងជាលក្ខណៈឯកជន ដូចជា ចំណងគ្រួសារ កូន និងទ្រព្យសម្បត្តិជាដើម។ ទំនាក់ទំនងខ្លះអាចប្រព្រឹត្តទៅដោយរលូន ចំណែកឯ ទំនាក់ទំនងខ្លះ ក៏ជួបប្រទះនឹងការបែកបាក់ប្រេះឆា និងឈានទៅដល់ការឈ្លោះប្រកែកគ្នា និងស្វែងរកដំណោះស្រាយរៀងៗខ្លួន។ ជាទូទៅភាគីដែលរងនូវវិវាទតែងតែធ្វើការផ្សះផ្សាគ្នាតាមរយៈមធ្យោបាយផ្សេងៗ ដូចជា ការចរចារ ការផ្សះផ្សា ការសម្របសម្រួល និងការដោះស្រាយគ្នាក្រៅប្រព័ន្ធតុលាការតាមមធ្យោបាយផ្សេងៗទៀត។

ក្នុងករណីដែលវិវាទមិនអាចត្រូវបានដោះស្រាយជាមួយគ្នាដោយជោគជ័យ នោះមានន័យថា ភាគីបរាជ័យក្នុងការដោះស្រាយវិវាទដោយខ្លួនឯង ហើយភាគីនៃវិវាទចាំបាច់ត្រូវតែបញ្ជូនវិវាទរបស់ខ្លួនទៅតុលាការដើម្បីធ្វើការដោះស្រាយតាមផ្លូវច្បាប់។ ដូច្នេះហើយវិវាទគឺជាដើមចមនៃបណ្តឹង ហើយបណ្តឹង គឺជាមូលហេតុដែលនាំឲ្យមានសេចក្តីសម្រេចរបស់តុលាការ។ ជាគោលការណ៍ យើងអាចនិយាយថា "បើគ្មានបណ្តឹង ក៏គ្មានសាលក្រមដែរ" ដោយហេតុថា បើគ្មានការទាមទារអះអាងពីភាគីណាមួយទេ តុលាការក៏គ្មានមូលហេតុគតិយុត្តណាដែលអាចធ្វើការចេញសេចក្តីសម្រេចបានដែរ។ បណ្តឹងត្រូវបានមនុស្សជាទូទៅទទួលស្គាល់ថា ជាមធ្យោបាយដែលនាំយកវិវាទរបស់ខ្លួនទៅឲ្យតុលាការដើម្បីធ្វើការដោះស្រាយ និងក៏ជាមូលហេតុដែលធ្វើឲ្យស្ថាប័នមួយនេះធ្វើការចេញសេចក្តីសម្រេចដោយផ្អែកលើនីតិវិធីដែលមានចែងក្នុងច្បាប់ជាធរមាន។

ការអនុវត្តសិទ្ធិរបស់បុគ្គលឯកជនតាមនីតិវិធីរដ្ឋប្បវេណី គឺជាសិទ្ធិរបស់ប្រជាពលរដ្ឋដែលត្រូវបានការពារដោយរដ្ឋ និងច្បាប់ ហេតុនេះ បុគ្គលឯកជណគ្រប់រូបមានសិទ្ធិដាក់ពាក្យបណ្តឹងទៅតុលាការដើម្បីការពារសិទ្ធិរបស់ខ្លួន ល្គឹកណាដែលសិទ្ធិទាំងនេះត្រូវបានគេបំពាននៅក្នុងវិវាទរដ្ឋប្បវេណី។ សិទ្ធិពឹងពាក់តុលាការ គឺជាសិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋ។

ទោះបីជាយ៉ាងណាក៏ដោយ ដើម្បីអាចឲ្យតុលាការទទួលយកបណ្តឹងមកធ្វើការដោះស្រាយបាន ភាគីដែលធ្វើការទាមទារ (ដើមចោទ) ត្រូវដាក់ពាក្យបណ្តឹងសរសេរជាលាយលក្ខណ៍អក្សរទៅតុលាការ លើកលែងតែមានបទបញ្ញត្តិផ្សេងទៀតដែលច្បាប់អនុញ្ញាតឲ្យធ្វើដោយផ្ទាល់មាត់បាន[1]។ ហើយដើម្បីឲ្យពាក្យបណ្តឹងមានភាពត្រឹមត្រូវដែលធ្វើឲ្យតុលាការទទួលយកមកធ្វើនីតិវិធីបាន ភាគីដែលទាមទារត្រូវគោរពនូវលក្ខខណ្ឌនៃបណ្តឹង ដូចជាផលប្រយោជន៍នៃបណ្តឹង[2] និងទម្រង់ខ្លឹមសារ

[1] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ២២៥ កថាខណ្ឌទី១

[2] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៧៥

នៃពាក្យបណ្តឹង[3] ទៅតាមអង្គហេតុជាក់ស្តែងដែលភាគីកំពុងជួបប្រទះ ជៀសវាង តុលាការធ្វើការបដិសេធមិនទទួលពាក្យបណ្តឹង ឬលើកពាក្យបណ្តឹងចោល។ ហើយបណ្តឹងនឹងអាចចាត់ទុកថាមានសុពលភាពនៅពេលដែលភាគីបានដាក់ទៅតុលាការ ដោយក្រឡាបញ្ជីបានបោះត្រាចូលថាបានទទួល បន្ទាប់មកដំណើរការនីតិវិធីនឹងត្រូវបានចាប់ផ្តើមតាមកំណត់ច្បាប់។

ហេតុដូច្នេះ តើបណ្តឹងជាអ្វី? ហើយអ្វីជា អង្គហេតុចម្បង? ហើយតើពាក្យបណ្តឹង មានទម្រង់បែបណា? តើចំណុចអ្វីខ្លះដែលត្រូវសរសេរក្នុងពាក្យបណ្តឹង? ដើម្បីងាយស្រួលធ្វើការបកស្រាយបញ្ហាគតិយុត្តទាំងអស់នេះ ក្រុមសិក្សាស្រាវជ្រាវយើងខ្ញុំ នឹងធ្វើការបង្ហាញជូនមិត្តអ្នកអាន និងអ្នកស្រាវជ្រាវគ្រប់ស្រទាប់វណ្ណៈនូវប្លង់សិក្សាជាពីរជំពូក៖ (១) បណ្តឹង និង (២) អង្គហេតុដែលជាមូលហេតុនៃការទាមទារ ឬ អង្គហេតុចម្បង ដែលនឹងធ្វើការលម្អិតជូនក្នុងខ្លឹមសារអត្ថបទខាងក្រោម៖

[3] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៧៥

# ជំពូកទី១
# បណ្តឹង

បណ្តឹង សំដៅលើសកម្មភាពទាមទារមួយដែលធ្វើឡើងដោយភាគីដើមចោទចំពោះចុងចម្លើយ ទៅកាន់តុលាការនៃការជំនុំជម្រះក្តីដោយអះអាងអំពីអត្ថភាព ឬ នត្ថិភាព ឬ ទំនាក់ទំនងគតិយុត្ត តាមផ្លូវច្បាប់ ហើយទាមទារឲ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារកំណត់មួយដោយផ្អែក ទៅលើការអះអាងនានា។ បន្ទាប់មក នីតិវិធីបណ្តឹងនឹងត្រូវបានចាប់ផ្តើម។

បុគ្គលណាក៏ដោយដែលមានសមត្ថភាពតាមផ្លូវច្បាប់សុទ្ធតែអាចធ្វើពាក្យបណ្តឹងបាន ដើម្បី ឲ្យតុលាការធ្វើសេចក្តីសម្រេចចំពោះការទាមទាររបស់ខ្លួន ហើយការធ្វើបណ្តឹងអាចធ្វើឡើងដោយ បុគ្គលខ្លួនឯងផ្ទាល់ ឬ តាមរយៈអ្នកតំណាងដោយអាណត្តិដែលខ្លួនបានជ្រើសរើស។ អ្នកតំណាង ដែលធ្វើសកម្មភាពបណ្តឹងក្នុងន័យនេះ គឺត្រូវតែជាមេធាវីលើកលែងតែមានករណីពិសេសមួយចំនួន[4] ដែលមានបញ្ញត្តិនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី។

កាលណាតុលាការទទួលបានពាក្យបណ្តឹង តុលាការអាចចាប់ផ្តើមនីតិវិធីបណ្តឹងដោយធ្វើ ការជំនុំជម្រះទៅលើបណ្តឹងនោះ និងចេញសេចក្តីសម្រេចតាមរយៈសាលក្រម។ សាលក្រម[5] គឺជា លទ្ធផលចុងក្រោយរបស់បណ្តឹង ដែលតុលាការត្រូវឆ្លើយតបទៅនឹងបណ្តឹងរបស់ភាគី តាមរយៈ ការទាមទារនានានៅក្នុងបណ្តឹង។ មានន័យថា បើភាគីទាមទារអ្វីមួយតុលាការត្រូវធ្វើការឆ្លើយតប ទៅនឹងការទាមទារនោះ បន្ទាប់ពីការយល់ឃើញរបស់ខ្លួន ឬ សម្អាងហេតុដែលកើតចេញពីអំណះ អំណាងរបស់គូភាគីដោយមានការផ្ទៀងផ្ទាត់ជាមួយនឹងភស្តុតាង។ ដូច្នេះ ជាគោលការណ៍ តុលាការ ធ្វើការជំនុំជម្រះ និងចេញសេចក្តីសម្រេចត្រឹមតែទំហំដែលភាគីបានទាមទារនៅក្នុងបណ្តឹងតែប៉ុណ្ណោះ លើកលែងតែបន្ទុកនៃប្រាក់ប្រដាប់ក្តី[6] ។

## ផ្នែកទី១. ទម្រង់នៃពាក្យបណ្តឹង

ទោះបីជាបណ្តឹងត្រូវបានធ្វើឡើងដោយភាគីខ្លួនឯងក្តី ឬ ធ្វើឡើងដោយអ្នកតំណាងរបស់ ខ្លួនក្តី (មេធាវី) ក៏ពាក្យបណ្តឹងទាំងនោះចាំបាច់ត្រូវតែគោរពតាមវិធានដែលបានកំណត់អំពីចំណុច ផ្សេងៗដែលត្រូវសរសេរនៅក្នុងពាក្យបណ្តឹងដោយអនុលោមតាមមាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។ ការយល់ដឹងអំពីវិធាននេះ គឺពិតជាមានសារៈសំខាន់ណាស់ ពីព្រោះថា ការធ្វេស ប្រហែសក្នុងការអនុវត្តតាមវិធាននេះអាចធ្វើឲ្យតុលាការបង្គាប់ឲ្យធ្វើការកែតម្រូវពាក្យបណ្តឹង ឬ លើក ពាក្យបណ្តឹងចោល។

---

[4] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៥៣

[5] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១៧៩

[6] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១៨២ កថាខណ្ឌទី១ ទី២ និងទី៣

### ១.១. ចំណុចដែលត្រូវសរសេរនៅក្នុងពាក្យបណ្ដឹង

ជាទូទៅពាក្យបណ្ដឹងគួតែសរសេរឲ្យបានពេញលេញដូចមានចែងក្នុងមាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ប៉ុន្តែនៅក្នុងមាត្រានេះមិនមែនចាំបាច់ត្រូវតែសរសេរទាំងអស់នោះទេ មានចំណុចខ្លះដើមចោទមិនចាំបាច់សរសេរក្នុងពាក្យបណ្ដឹងក៏បាន ចាំអះអាងនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលក៏បាន។ ហើយចំណុចខ្លះដែលចាំបាច់ត្រូវសរសេរក្នុងពាក្យបណ្ដឹង មានបញ្ញត្តិក្នុងមាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រង់កថាខណ្ឌទី២ ចំណុច ក និង ខ ។

#### ១.១.១. អត្តសញ្ញាណរបស់គូភាគី

យោងតាមមាត្រា ៧៥ កថាខណ្ឌទី២ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណី នៅក្នុងពាក្យបណ្ដឹងដើមចោទ ឬ មេធាវី ត្រូវសរសេរជាចាំបាច់នូវ ឈ្មោះ ឬ នាមករណ៍ និងអាសយដ្ឋានរបស់គូភាគី ព្រមទាំងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងឲ្យបានច្បាស់លាស់ (បើមាន)។

ភាគី គឺជាចំណុចចាំបាច់ដែលត្រូវសរសេរក្នុងពាក្យបណ្ដឹងដើម្បីបញ្ជាក់ថា អ្នកណាជាដើមចោទ ហើយអ្នកណាជាចុងចម្លើយ។ បើជារូបវន្តបុគ្គលត្រូវសរសេរឈ្មោះបុគ្គលនោះ ព្រមទាំងអាសយដ្ឋានឲ្យបានច្បាស់លាស់ តែបើជានីតិបុគ្គលវិញ ត្រូវសរសេរនាមករណ៍ ឬ ឈ្មោះ និងទីតាំងនៃទីស្នាក់ការនៃនីតិបុគ្គល និងអត្តសញ្ញាណនៃអ្នកតំណាង។

ជាគោលការណ៍ អានុភាពនៃសាលក្រមដែលចេញដោយតុលាការនឹងមានអានុភាពទៅលើភាគី ហើយចងកាតព្វកិច្ចភាគីនោះ[7]។ ពេលដែលពាក្យបណ្ដឹងត្រូវបានដាក់ហើយ តុលាការត្រូវមានករណីកិច្ចធ្វើការវិនិច្ឆ័យស្ដីពីវិវាទរវាងដើមចោទ និងចុងចម្លើយនោះ ហើយក្នុងករណីដែលមានការភ័ន្តច្រឡំភាគី ឬ មិនស្គាល់ភាគីនោះ សាលក្រមនឹងមិនអាចអនុវត្តទៅបាន ឬ អាចប៉ះពាល់ដល់ផលប្រយោជន៍របស់តតិយជន។

ចំណុចសំខាន់មួយទៀតដែលមេធាវី ឬ អ្នកសិក្សាផ្នែកច្បាប់ទូទៅត្រូវតែយកចិត្តទុកដាក់នោះគឺ សមត្ថភាពរបស់ភាគីក្នុងការធ្វើបណ្ដឹង និងអ្នកតំណាងដែលច្បាប់បានកំណត់សម្រាប់ជនដែលគ្មានសមត្ថភាពក្នុងការធ្វើបណ្ដឹង[8] ព្រោះថា មានតែបុគ្គលដែលមានសិទ្ធិ និងករណីកិច្ចតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី និងច្បាប់ផ្សេងទៀតទេដែលអាចទទួលនូវឋានៈជាភាគីដើមចោទ ឬ ភាគីចុងចម្លើយ។

ដោយឡែកចំណុចដែលត្រូវសរសេរបញ្ជាក់ពីអ្នកតំណាងដោយអាណត្តិ មិនមែនជាករណីចំបាច់នោះទេនៅក្នុងការសរសេរពាក្យបណ្ដឹង។ មានន័យថា ទោះបីជាមិនបានសរសេរចំណុចនេះក្នុងពាក្យបណ្ដឹងក៏ដោយ ក៏មិនមែនជាមូលហេតុដែលតុលាការបង្គាប់ឲ្យធ្វើការកែតម្រូវពាក្យបណ្ដឹងនោះដែរ។

---

[7] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១៩៨ ចំណុច ក

[8] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៣២

### ១.១.២. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ

ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ គឺជាអត្ថន័យនៃការទាមទារដែលដើមចោទចង់ឲ្យតុលាការសម្រេចសេចក្តីដូចបានសរសេរក្នុងពាក្យបណ្តឹងរបស់ខ្លួន។ ការទាមទាររបស់ដើមចោទត្រូវតែជាការទាមទារដែលមានផលប្រយោជន៍ និងត្រូវបានកំណត់ដោយច្បាប់សារធាតុ[9] ហើយត្រូវសរសេរនូវខ្លឹមសារទាំងអស់នោះឲ្យបានច្បាស់លាស់ក្នុងពាក្យបណ្តឹងដោយបញ្ជាក់អំពីអង្គហេតុបង្កើតសិទ្ធិទាមទារ ឬអង្គហេតុរំលាយសិទ្ធិទាមទារ ដើម្បីឲ្យតុលាការចេញសេចក្តីសម្រេច។ ការសរសេរអំពីខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញនៅក្នុងពាក្យបណ្តឹងមានភាពខុសប្លែកគ្នាទៅតាមប្រភេទនៃបណ្តឹង។ខ្លឹមសារនៃសាលក្រមត្រូវបញ្ជាក់អំពីកម្មវត្ថុដែលត្រូវវិនិច្ឆ័យក្នុងពាក្យបណ្តឹង ទំហំ ឬកម្រិតនៃការវិនិច្ឆ័យដោយតុលាការ ។

**ឧទាហរណ៍:**

<u>បណ្តឹងទាមទារឲ្យផ្តល់តាវកាលិក៖</u> បង្គាប់ឲ្យចុងចម្លើយឈ្មោះ Y បង់ប្រាក់ចំនួន ១០.០០០ ដុល្លារ ជាមួយការប្រាក់ ៥ % ក្នុងមួយឆ្នាំ រហូតដល់ថ្ងៃសងរួចទៅឲ្យដើមចោទឈ្មោះ X ដោយផ្អែកលើកិច្ចសន្យាខ្ចីបរិភោគ។

<u>បណ្តឹងទាមទារឲ្យបញ្ជាក់៖</u> បញ្ជាក់ថា ដើមចោទ X មានកម្មសិទ្ធិលើដី L ដែលមានទំហំ ១០x២០ ម៉ែត្រក្រឡា ដែលមានទីតាំងស្ថិតនៅជាប់ផ្សារអូឬស្សី។

<u>បណ្តឹងទាមទារឲ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្តិ៖</u> ឲ្យដើមចោទ X លែងលះ ជាមួយចុងចម្លើយ Y ។

### ១.១.៣. អង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ

អង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ គឺជាអង្គហេតុចាំបាច់សម្រាប់បញ្ជាក់បង្ហាញអំពីការអះអាងអំពីសិទ្ធិដែលជាមូលដ្ឋាន ឬជាសម្អាងចំពោះការទាមទារតាមផ្លូវបណ្តឹងដែលដើមចោទទាមទារឲ្យតុលាការធ្វើការជំនុំជម្រះ និងចេញសាលក្រម ឬ អង្គហេតុដែលកំណត់អំពីសិទ្ធិណាមួយ។

ឧទាហរណ៍៖ ទាមទារឲ្យចុងចម្លើយសងប្រាក់ចំនួន ១ ០០០ ដុល្លារ ដោយផ្អែកលើកិច្ចសន្យាខ្ចីបរិភាគ ឬកិច្ចសន្យាទិញ លក់។

ហេតុផលចាំបាច់ ដែលត្រូវសរសេរអំពីអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារក្នុងពាក្យបណ្តឹង គឺដើម្បីកុំឲ្យមានការភ័ន្តច្រឡំ ឬមានការបែងចែកមិនច្បាស់លាស់នូវការទាមទារដែលជាកម្មវត្ថុនៃការជំនុំជម្រះ និងសម្រេចសេចក្តីទៅនឹងការទាមទារផ្សេងទៀត។ ដូច្នេះ អង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារសំដៅលើអង្គហេតុដែលអាចធ្វើការសម្គាល់កុំឲ្យមានការភ័ន្តច្រឡំរវាងសិទ្ធិ ឬ

[9] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៧៤

ទំនាក់ទំនងគតិយុត្តដែលជាមូលដ្ឋាននៃការទាមទារដោយដើមចោទ និងសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដទៃទៀត។ ហើយអង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារនេះ គឺមានភាពខុសគ្នាទៅតាមប្រភេទនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តនីមួយៗ[10]។

**ក. ករណីដែលសិទ្ធិអះអាងដោយដើមចោទ ជាសិទ្ធិប្រត្យក្ស**

សិទ្ធប្រត្យក្ស ជាសិទ្ធិផ្តាច់មុខ។ មានន័យថា មិនអាចមានអត្ថិភាពនៃសិទ្ធិប្រត្យក្សដូចគ្នាជាន់គ្នាលើកម្មវត្ថុតែមួយបានឡើយ (ឧទាហរណ៍: មិនអាចមានកម្មសិទ្ធិពីរលើដីតែមួយបានឡើយ លើកលែងតែកម្មសិទ្ធិអវិភាគ)។ ហេតុដូចនេះ ដើម្បីធ្វើការបញ្ជាក់នូវសិទ្ធិ ដើមចោទគ្រាន់តែសរសេរអំពីប្រធាននៃសិទ្ធិ (ឧទាហរណ៍: ដើមចោទ) កម្មវត្ថុនៃសិទ្ធិ (ឧទាហរណ៍: ដីនៅកន្លែងណាមួយ) ព្រមទាំងប្រភេទ និងខ្លឹមសារនៃសិទ្ធិ (ឧទាហរណ៍: សិទ្ធិកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ ជាដើម) ជាការគ្រប់គ្រាន់ប្រសិនបើសិទ្ធិដែលអះអាងដោយដើមចោទ ជាសិទ្ធិប្រត្យក្ស។

**ខ. ករណីដែលសិទ្ធិអះអាងដោយដើមចោទ ជាសិទ្ធិលើបំណុល**

ផ្ទុយពីសិទ្ធិប្រត្យក្ស ដើមចោទអាចមានសិទ្ធិលើបំណុលច្រើនចំពោះចុងចម្លើយដោយមានមូលហេតុនៃការបង្កើតសិទ្ធិផ្សេងគ្នា។ ហេតុនេះ ក្នុងករណីដែលសិទ្ធិអះអាងដោយដើមចោទជាសិទ្ធិលើបំណុល ដើម្បីធ្វើការបញ្ជាក់នូវសិទ្ធិ ដើមចោទត្រូវសរសេរនៅក្នុងពាក្យបណ្តឹងអំពីប្រធាននៃសិទ្ធិ (ឧទាហរណ៍: ដើមចោទ) កម្មវត្ថុនៃសិទ្ធិ (ឧទាហរណ៍: ចុងចម្លើយ) ប្រភេទ និងខ្លឹមសារនៃសិទ្ធិ (ឧទាហរណ៍: សិទ្ធិទាមទារឲ្យបង់ប្រាក់ចំនួន១០.០០០ ដុល្លារ) ព្រមទាំងមូលហេតុនៃការបង្កើតសិទ្ធិ (ឧទាហរណ៍: កិច្ចសន្យាខ្ចីបរិភោគ កិច្ចសន្យាលក់ទិញ គ្រោះថ្នាក់ចរាចរណ៍ដែលកើតឡើងនៅកាលបរិច្ឆេទណាមួយ) នោះផង។

## ១.២. ចំណុចដែលគប្បីសរសេរនៅក្នុងពាក្យបណ្តឹង

ត្រង់ចំណុចទី៣ និងទី៤ នៃមាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី បើទោះបីជាភាគីដើមចោទមិនបានសរសេរក្នុងពាក្យបណ្តឹងក៏ដោយ ក៏តុលាការមិនបង្គាប់ឲ្យធ្វើការកែតម្រូវដែរ ពីព្រោះចំណុចទាំងនេះ មិនតម្រូវឲ្យសរសេរជាដាច់ខាតនោះទេ។ ប៉ុន្តែដើម្បីឲ្យមានភាពងាយស្រួល ជាពិសេសឲ្យតុលាការអាចយល់ដឹងបាន ភាគីដើមចោទគួគប្បីសរសេរឲ្យបានពេញលេញ។

### ១.២.១. អង្គហេតុដែលជាមូលហេតុនៃការទាមទារ

អង្គហេតុដែលជាមូលហេតុនៃការទាមទារ គឺជាអង្គហេតុចម្បងដែលបង្កើតនូវសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលជាសិទ្ធិទាមទារតាមផ្លូវបណ្តឹងរបស់ដើមចោទដែលជួយបញ្ជាក់អំពីអត្ថិភាព ឬ នត្ថិ-ភាពនៃសិទ្ធិទាមទារឲ្យកាន់តែច្បាស់លាស់។

[10] ទំព័រទី៥៤ និងចំណុចបន្តបន្ទាប់នៃសៀវភៅ សេចក្តីពន្យល់អំពីក្រមនីតិវិធីភាគ១: នីតិវិធីបណ្តឹង និងដកស្រង់ចេញពី សៀវភៅស្តីពីការពន្យល់អំពីការជំនុំជម្រះលើកទី១ (បោះពុម្ពលើកទី២) ទំព័រទី៦

ដើម្បីស្វែងយល់អង្គហេតុទាំងនេះឲ្យបានច្បាស់លាស់ គេត្រូវពិនិត្យភាពខុសគ្នារវាងអង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ និងអង្គហេតុដែលជាមូលហេតុនៃការទាមទារ។

ការសរសេរអំពី "អង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ" នៅក្នុងពាក្យបណ្តឹងគឺដើម្បីបែងចែកឲ្យច្បាស់លាស់នូវការទាមទារតាមផ្លូវបណ្តឹងពីការទាមទារផ្សេងទៀត ដែលដើមចោទត្រូវបំភ្លឺឲ្យបានច្បាស់លាស់នៅដំណាក់កាលនៃការទាមទារ ចំណែកឯ ការសរសេរ "អង្គហេតុដែលជាមូលហេតុនៃការទាមទារ" នៅក្នុងពាក្យបណ្តឹង គឺដើម្បីបង្ហាញអំពីការកើតមានឡើងនៃការទាមទារតាមផ្លូវបណ្តឹងរបស់ដើមចោទ ដែលត្រូវបំភ្លឺឲ្យបានច្បាស់លាស់នៅដំណាក់កាលនៃការអះអាង។

ឧទាហរណ៍៖ X (ដើមចោទ) ឲ្យ Y (ចុងចម្លើយ) ខ្ចីប្រាក់ចំនួន ១០.០០០ ដុល្លារ តាមកិច្ចសន្យាខ្ចីបរិភោគ ដែលបានបង្កើតឡើងនៅថ្ងៃទី០១ ខែមិនា ឆ្នាំ ២០១៧ ដោយកំណត់កាលបរិច្ឆេទសងនៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ ២០១៧។

ដើម្បីទាមទារប្រាក់កម្ចីខាងលើតាមរយៈបណ្តឹងទៅតុលាការ ដើមចោទត្រូវធ្វើការអះអាងនូវអង្គហេតុដូចខាងក្រោម៖

**ក. អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ:** ឲ្យប្រធាននៃសិទ្ធិ (ចុងចម្លើយ) កម្មវត្ថុនៃសិទ្ធិ (សងប្រាក់កម្ចី) ប្រភេទ និងខ្លឹមសារនៃសិទ្ធិ ព្រមទាំងមូលហេតុនៃការកកើតនៃសិទ្ធិដែលដើមចោទធ្វើការទាមទារតាមផ្លូវបណ្តឹង (កិច្ចសន្យាខ្ចីបរិភោគ)។

**ខ. អង្គហេតុដែលជាមូលហេតុនៃការទាមទារ:** មានអង្គហេតុចំនួនពីរទៀតដែលត្រូវបង្ហាញ គឺដើមចោទបានប្រគល់ប្រាក់ចំនួន ១០.០០០ ដុល្លារ ឲ្យចុងចម្លើយ ហើយកាលកំណត់សង គឺនៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ ២០១៧ ក៏បានកន្លងផុតទៅហើយដែរ។

អង្គហេតុដែលជាមូលហេតុនៃការទាមទារ ជាចំណុចដែលដើមចោទគួគប្បីសរសេរនៅក្នុងពាក្យបណ្តឹង ពីព្រោះតែវាបានផ្តល់នូវផលប្រយោជន៍ដល់ដំណើរការនៃនីតិវិធីដូចខាងក្រោម៖

១. អាចឲ្យតុលាការរៀបចំចំណុចវិវាទបានងាយស្រួលតាំងពីកាលបរិច្ឆេទលើកដំបូង។

២. ករណីបើចុងចម្លើយអវត្តមាន តុលាការអាចចេញសាលក្រមកំបាំងមុខ[11] ដោយពុំចាំបាច់ធ្វើការបញ្ជូនជាថ្មីនូវខ្លឹមសារនៃសេចក្តីថ្លែងការណ៍របស់ដើមចោទ ទៅចុងចម្លើយតាមមាត្រា ២០២ ចំណុច ឃ ឡើយ។

### ១.២.២.អង្គហេតុសំខាន់ៗដែលទាក់ទងនឹងអង្គហេតុដែលជាមូលហេតុនៃការទាមទារ (អង្គហេតុប្រយោល)

ជាទូទៅតុលាការធ្វើការសម្រេចសេចក្តីដោយផ្អែកលើភស្តុតាង និងអង្គហេតុដែលអាចបញ្ជាក់អំពីការទាមទារ។ ភស្តុតាង និងអង្គហេតុបែបនេះ គេហៅថា **ភស្តុតាង និងអង្គហេតុផ្ទាល់**។ ក៏ប៉ុន្តែ

[11] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ២០១ កថាខណ្ឌទី១ និងទី២

ក្នុងករណីខ្លះ ដើមចោទមិនមានភស្តុតាងផ្ទាល់ និងអង្គហេតុផ្ទាល់ដែលអាចបញ្ជាក់អំពីការទាមទារឡើយ។ ក្នុងករណីបែបនេះ ដើម្បីអាចឲ្យតុលាការជឿជាក់លើការទាមទារ ដើមចោទត្រូវបង្ហាញនូវភស្តុតាង និងអង្គហេតុផ្សេងៗដើម្បីគាំទ្រអង្គហេតុផ្ទាល់របស់ខ្លួន។ អង្គហេតុប្រភេទនេះ គេហៅថា **អង្គហេតុប្រយោល**។

អង្គហេតុប្រយោល គឺជាអង្គហេតុទាំងឡាយណាដែលអាចធ្វើឲ្យគេអាចសន្និដ្ឋានអំពីអត្ថិភាព ឬ នត្ថិភាពនៃអង្គហេតុចម្បង។ គេអាចប្រើវាបានក្នុងករណីណាដែលមានការខ្វះខាតនូវភស្តុតាងផ្ទាល់ដើម្បីបញ្ជាក់អង្គហេតុចម្បង។ ផ្ទុយទៅវិញ ប្រសិនបើមានភស្តុតាងផ្ទាល់ច្បាស់លាស់ហើយ គេមិនចាំបាច់សរសេរអង្គហេតុប្រយោលក៏បាន។

ឧទាហរណ៍៖ ដើម្បីបញ្ជាក់អំពីអង្គហេតុចម្បង " X បានឲ្យប្រាក់ទៅ Y ខ្ចីចំនួន ៩០០ដុល្លារ" ដើមចោទអាចអះអាងនូវអង្គហេតុប្រយោលដូចតទៅ " X បានដកប្រាក់ពីធនាគារចំនួន ៩០០ ដុល្លារ មុនពេលឲ្យប្រាក់ទៅ Y ខ្ចី ហើយ Y បានទិញម៉ូតូមួយគ្រឿងក្នុងតម្លៃ ប្រហែល ៩០០ ដុល្លារ ក្រោយពេលឲ្យខ្ចី។ នៅក្នុងឧទាហរណ៍នេះ ករណី X បានឲ្យប្រាក់ទៅ Y ខ្ចី ជាអង្គហេតុចម្បង។ ចំណែកឯការទៅដកប្រាក់នៅធនាគាររបស់ X និងការទិញម៉ូតូរបស់ Y គឺមានភាពស៊ីសង្វាក់គ្នាដែលធ្វើឲ្យដើមចោទអាចអះអាងនៅក្នុងអង្គហេតុប្រយោលបាន។

### ១.២.៣. ភស្តុតាង

យោងតាមមាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ភស្តុតាង ពុំមានចែងតម្រូវឲ្យចាំបាច់ត្រូវតែភ្ជាប់ជាមួយនឹងពាក្យបណ្តឹងនោះទេ ប៉ុន្តែដើម្បីបង្កភាពងាយស្រួលឲ្យតុលាការងាយយល់ និងដើម្បីដំណើរការនីតិវិធីបានលឿន ដើមចោទ ឬ តំណាងដោយអាណត្តិរបស់ដើមចោទគប្បីភ្ជាប់ជាមួយនូវភស្តុតាងក្នុងពាក្យបណ្តឹង។

ភស្តុតាងក្នុងរឿងក្តីរដ្ឋប្បវេណីមាន ៥ ប្រភេទគឺ (ក) ការសាកសួរសាក្សី (ខ) ការសាកសួរភាគី (គ) កោសលវិច័យ (ឃ) ភស្តុតាងជាឯកសារ និង (ង) កាត្រួតពិនិត្យ។

#### ក. ការសាកសួរសាក្សី

ជាគោលការណ៍តុលាការអាចសាកសួរជនណាក៏បាន[12] ក្នុងនោះក៏មានសាក្សីផងដែរ។ សាក្សីគឺជាតតិយជនដែលត្រូវបានតុលាការបង្គាប់ឲ្យធ្វើសេចក្តីរាយការណ៍ជូនតុលាការស្តីពីអង្គហេតុនៃអតីតកាលដែលខ្លួនបានជួបប្រទះដោយខ្លួនឯងនៅក្រៅបណ្តឹង។ ហើយជាគោលការណ៍ សាក្សីទាំងអស់ត្រូវធ្វើសម្បថ[13] ហើយសេចក្តីថ្លែងការរបស់សាក្សី គេហៅថា **ចម្លើយជាកសិណសាក្សី**។

[12] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១៣២

[13] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១៣៧

ជនណាដែលត្រូវបានតុលាការកោះហៅជាសាក្សី មានករណីកិច្ចបង្ហាញខ្លួននៅចំពោះមុខតុលាការ លើកលែងតែមានករណីដែលកំណត់ដោយក្រមនីតិវិធីរដ្ឋប្បវេណី ឬ ច្បាប់ផ្សេងទៀត។ តុលាការអាចបង្គាប់ឲ្យនាំខ្លួនសាក្សីដែលមិនព្រមចូលខ្លួនមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវដោយដីកាសម្រេច ឬ អាចធ្វើការពិន័យចំពោះការមិនព្រមចូលខ្លួនដោយគ្មានមូលហេតុត្រឹមត្រូវជាប្រាក់មិនឲ្យលើសពីចំនួន ១.០០០.០០០ រៀល[14]។ ម្យ៉ាងទៀត សាក្សីអាចបដិសេធក្នុងការផ្តល់ចម្លើយជាកសិណសាក្សីបានចំពោះចំណុចដែលអាចធ្វើឲ្យសាមីខ្លួន ឬ សហព័ទ្ធរបស់សាក្សី ឬ សាច់ញាតិដទៃទៀតទទួលរងការចោទប្រកាន់ពីបទអាជ្ញា ឬ ទទួលរងការផ្តន្ទាទោស ឬ ចំពោះចំណុចដែលជាការសម្ងាត់[15]។

ជាគោលការណ៍ ការសាកសួរសាក្សីត្រូវធ្វើឡើងនៅចំពោះមុខតុលាការដែលចាត់ការលើបណ្តឹងនោះនៅក្នុងសាលសវនាការដែលបើកចំហជាសាធារណៈ ប៉ុន្តែក្នុងករណីដែលសាក្សីមិនអាចបង្ហាញខ្លួនចំពោះមុខតុលាការបាន ដោយសារជម្ងឺ ឬ ភាពចាស់ជរា ជាដើម តុលាការអាចធ្វើការសាកសួរជាពិសេសនៅក្រៅតុលាការបាន[16]។

**នីតិវិធីនៃការសាកសួរសាក្សី មានដូចខាងក្រោមៈ**

**១. ការសាកសួរអំពីអត្តសញ្ញាណរបស់សាក្សី**

- សួរអំពីឈ្មោះ ថ្ងៃ ខែ ឆ្នាំ កំណើត
- អាសយដ្ឋាន
- មុខរបរ ជាដើម។

**២. ការធ្វើសម្បថ**

- សាក្សី ត្រូវតែធ្វើសម្បថមុនពេលសាកសួរ លើកលែងតែសាក្សីដែលមានចែងក្នុងមាត្រា ១៣៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។
- សម្បថត្រូវដឹកនាំដោយក្រឡាបញ្ជី[17]
- ត្រូវធ្វើនៅចំពោះមុខនៃកន្លែងធ្វើពិធីសម្បថនៅតាមតុលាការនីមួយៗ
- ក្រោយពីធ្វើសម្បថ ក្រឡាបញ្ជីត្រូវធ្វើការកំណត់អំពីសម្បថ។

[14] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១៣២ កថាខណ្ឌទី២ និងទី៣

[15] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១៣៤

[16] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១៣៦ កថាខណ្ឌទី១

[17] ត្រូវអុជទៀន ធូប ក្រឡាបញ្ជីត្រូវអានប្រារព្ធវាទខ្លាំងៗ និងអានពាក្យសច្ចាប្រណិធានឲ្យអ្នកស្បថថាតាម

**៣. ការក្រមិតសំណួរដែលត្រូវសួរ**

– ត្រូវធ្វើដាច់ដោយឡែក និងច្បាស់លាស់[18]។

– មិនត្រូវសួរសំណួរនាំមុខឡើយ។

– មិនត្រូវសួរសំណួរច្រំដែល។

– មិនត្រូវសួរសំណួរដែលគ្មានទំនាក់ទំនងនឹងចំណុចវិវាទ។

– សំណួរដែលប្រមាថមើលងាយ ឬ ធ្វើឲ្យច្របូកច្របល់ដល់សាក្សី។ល។

**ខ. ការសាកសួរភាគី**

ការសាកសួរភាគី គឺជានីតិវិធីដែលមានគោលបំណងទទួលយកនូវធនធានភស្តុតាងដោយយកសាមីភាគីជាកម្មវត្ថុនៃការពិនិត្យ ដោយឲ្យភាគីធ្វើសេចក្តីថ្លែងការណ៍អំពីអង្គហេតុដែលខ្លួនបានជួបប្រទះផ្ទាល់នោះ តាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិរបស់តុលាការ។

**គ. កោសលវិច័យ**

កោសលវិច័យ គឺជាការពិនិត្យភស្តុតាងដែលតុលាការកំណត់ឲ្យតតិយជន (អ្នកជំនាញខាងកោសលវិច័យ) ដែលមានចំណេះវិជ្ជា និងបទពិសោធន៍ពិសេសឲ្យធ្វើរបាយការណ៍ទៅតាមជំនាញបទពិសោធន៍ដែលខ្លួនបានដឹងតាមចំណេះវិជ្ជារបស់ខ្លួន ឬ ធ្វើរបាយការណ៍អំពីការវិនិច្ឆ័យ ឬយោបល់ដែលបានមកពីការអនុវត្តវិធានតាមបទពិសោធន៍ជំនាញ ចំពោះអង្គហេតុជាក់ស្តែងដែលជាបញ្ហានៅក្នុងបណ្តឹងនោះ។ តុលាការជាអ្នកកំណត់អ្នក ជំនាញខាងធ្វើកោសលវិច័យ ហើយអ្នកជំនាញទាំងនោះ មានករណីកិច្ចត្រូវធ្វើកិច្ចកោសលវិច័យ[19]។ ក្នុងករណីដែលមានហេតុរារាំងដល់សច្ចភាពនៃការធ្វើកោសលវិច័យរបស់អ្នកជំនាញ ភាគីអាចប្តឹងជាត់ចោលអ្នកធ្វើកោសលវិច័យនោះបាន[20]។

**ឃ. ភស្តុតាងជាឯកសារ**

ជាទូទៅឯកសារដែលចាត់ទុកជាភស្តុតាងបាន លុះត្រាតែឯកសារនោះត្រូវបានបង្កើតឡើងដោយត្រឹមត្រូវ។ មានន័យថា ឯកសារនោះត្រូវបានបង្កើតឡើងដោយបុគ្គលជាក់លាក់ដូចដែលបានអះអាងដោយភាគីដែលបានស្នើសុំឲ្យពិនិត្យភស្តុតាងនោះ។

ភស្តុតាងជាឯកសារត្រូវបានចែកចេញជាពីរប្រភេទ គឺ ឯកសាធារណៈ និងឯកសារឯកជន។

---

[18] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១៣៩ កថាខណ្ឌទី១

[19] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១៤៤ កថាខណ្ឌទី១ និងទី២

[20] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១៤៥

**១. ឯកសារសាធារណៈ**

ឯកសារសាធារណៈ គឺជាឯកសារដែលធ្វើឡើងដោយមន្ត្រីរាជការក្នុងការបំពេញមុខនាទីរបស់ខ្លួនដោយផ្អែកលើសិទ្ធិអំណាចសាធារណៈ ដូចជា សាលក្រម កំណត់ហេតុនៃការទាញហេតុផលដោយផ្ទាល់មាត់ ឯកសារដែលមានសេចក្តីបញ្ជាក់នៃសៀវភៅគោលបញ្ជីដីធ្លី ជាដើម គឺជាឯក-សារសាធារណៈ។ ក្នុងការត្រួតពិនិត្យឯកសារសាធារណៈ តុលាការមិនចាំបាច់ធ្វើការបញ្ជាក់ពីភាពត្រឹមត្រូវនៃការបង្កើតឯកសារនោះទេ[21] ប្រសិនបើឯកសារនោះត្រូវបានធ្វើឡើងដោយមន្ត្រីរាជការដែលមានមុខនាទីតាមទម្រង់ និងខ្លឹមសារនៃឯកសារឲ្យ។

**២. ឯកសារឯកជន**

ឯកសារឯកជន ជាឯកសារក្រៅពីឯកសារសាធារណៈ។ ឯកសារឯកជន ជាឯកសារបង្កើតឡើងដោយបុគ្គលឯកជន និងបុគ្គលឯកជន ឬ អ្នកតំណាងរបស់បុគ្គលនោះ។ ចំពោះឯកសារឯកជនភាគីត្រូវធ្វើការបញ្ជាក់អំពីភាពត្រឹមត្រូវក្នុងការបង្កើតឯកសារនោះ ក៏ប៉ុន្តែ ចំពោះឯកសារដែលមានចុះហត្ថលេខាដោយសាមីខ្លួន ឬ អ្នកតំណាង (អ្នកដែលបានធ្វើឯកសារ) នោះត្រូវសន្មតថា ជាឯកសារដែលបានធ្វើដោយត្រឹមត្រូវ [22]។

ហេតុដូច្នេះ ភាគីម្ខាងទៀតដែលធ្វើវិវាទអំពីភាពត្រឹមត្រូវនៃការបង្កើតឯកសារឯកជនបែបនេះចាំបាច់ត្រូវធ្វើការបញ្ជាក់ថា ឯកសារនោះត្រូវបានបង្កើតឡើងដោយខុសពីឆន្ទៈរបស់អ្នកដែលបង្កើតឯកសារ។

**ង. ការត្រួតពិនិត្យ**

ការត្រួតពិនិត្យ គឺជាការពិនិត្យភស្តុតាងដើម្បីទទួលបាននូវធនធានភស្តុតាងដោយការត្រួតពិនិត្យនូវភិនភាគ ឬ បាតុភូតនៃវត្ថុដោយផ្ទាល់ដោយចៅក្រម តាមរយៈវិញ្ញាណទាំងប្រាំរបស់ខ្លួន (ចក្ខុវិញ្ញាណ សោតវិញ្ញាណ កាយវិញ្ញាណ ឃានវិញ្ញាណ ជីវ្ហាវិញ្ញាណ)។ វត្ថុ ឬ មនុស្សដែលជាកម្មវត្ថុនៃការត្រួតពិនិត្យនោះ គេហៅថា វត្ថុដែលត្រូវពិនិត្យ[23]។

ការត្រួតពិនិត្យ មិនមែនជាការពិនិត្យនៅលើខ្លឹមសារដែលមាននៅក្នុងវត្ថុណាមួយប៉ុណ្ណោះទេពោលគឺ ជាការពិនិត្យទៅលើលក្ខណៈ ធាតុ បាតុភូតនៃឯកសារ ដូចជាការពិនិត្យទៅលើលក្ខណៈប្រភេទនៃក្រដាសដែលបានកត់ត្រា ឬ សរសេរ ឬ លក្ខណៈនៃអក្សរ តែពុំមែនជាខ្លឹមសារនៃការសរសេរឡើយ។

[21] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១៥៥ កថាខណ្ឌទី២

[22] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១៥៥ កថាខណ្ឌទី៤

[23] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១៦១

ការបង្ហាញនូវកម្មវត្ថុដែលត្រូវត្រួតពិនិត្យត្រូវយកមកអនុវត្តដូចគ្នាចំពោះការបង្ហាញ ឬ ការផ្ញើមកនូវកម្មវត្ថុដែលត្រូវត្រួតពិនិត្យ។ ក្នុងករណីដែលតតិយជនមិនព្រមធ្វើតាមដីកាបង្គាប់ឲ្យបង្ហាញដូចដែលបានកំណត់នៅក្នុងមាត្រា ១៥២ កថាខណ្ឌទី១ (ដីកាបង្គាប់ឲ្យផ្តល់ឯកសារ ជាអាទិ៍) ដោយគ្មានមូលហេតុត្រឹមត្រូវ តុលាការអាចពិន័យជាប្រាក់ដោយកំណត់ចំនួនមិនលើសពី ពីរលានរៀលដោយដីកាសម្រេចបាន[24]។

## ផ្នែកទី២. ប្រភេទនៃបណ្តឹង

ដើម្បីអាចឲ្យតុលាការ ចេញសាលក្រមឆ្លើយតបនឹងការទាមទារតាមផ្លូវបណ្តឹងណាមួយបានភាគីដែលដាក់ពាក្យបណ្តឹង និងតុលាការដែលទទួលពាក្យបណ្តឹងត្រូវយល់ដឹងអំពីប្រភេទនៃបណ្តឹងដែលត្រូវបែងចែកទៅតាមបទដ្ឋានផ្សេងៗគ្នា។ យោងតាមក្រមនីតិវិធីរដ្ឋប្បវេណីជាធរមាន បណ្តឹងក្នុងរឿងក្តីរដ្ឋប្បវេណីត្រូវបានបែងចែកជា ៣ (បី) ប្រភេទធំៗគឺៈ បណ្តឹងទាមទារឲ្យផ្តល់តាវកាលិក បណ្តឹងទាមទារឲ្យបញ្ជាក់ និងបណ្តឹងទាមទារឲ្យបង្កើត ប្តូរ ឬ រំលត់នូវទំនាក់ទំនងគតិយុត្ត។

### ២.១. បណ្តឹងទាមទារឲ្យផ្តល់តាវកាលិក

បណ្តឹងទាមទារឲ្យផ្តល់តាវកាលិក គឺជាបណ្តឹងមួយដែលទាមទារឲ្យតុលាការចេញសាលក្រមបង្គាប់ឲ្យចុងចម្លើយផ្តល់តាវកាលិកកំណត់មួយ ដោយផ្អែកលើការអះអាងអំពីអត្ថិភាពនៃសិទ្ធិទាមទាររបស់ដើមចោទផ្អែកតាមផ្លូវច្បាប់សារធាតុ។

បណ្តឹងទាមទារឲ្យផ្តល់តាវកាលិកមានពីរប្រភេទគឺៈ ប្រភេទបណ្តឹងទាមទារឲ្យផ្តល់តាវកាលិកនាពេលបច្ចុប្បន្ន និងប្រភេទបណ្តឹងទាមទារឲ្យផ្តល់តាវកាលិកនាពេលអនាគត។

#### ២.១.១. បណ្តឹងទាមទារឲ្យផ្តល់តាវកាលិកនាពេលបច្ចុប្បន្ន

បណ្តឹងទាមទារឲ្យផ្តល់តាវកាលិកនាពេលបច្ចុប្បន្ន សំដៅលើបណ្តឹងដែលធ្វើឡើងដោយដើមចោទ ដោយអះអាងអំពីសិទ្ធិទាមទារឲ្យផ្តល់តាវកាលិកមួយដែលពេលកំណត់នៃការអនុវត្តនោះបានមកដល់ ឬ បានកន្លងផុតហើយ ឬ អាចនិយាយម្យ៉ាងទៀតថា បណ្តឹងទាមទារឲ្យផ្តល់តាវកាលិកនាពេលបច្ចុប្បន្ន គឺជាបណ្តឹងទាមទារឲ្យផ្តល់តាវកាលិកដែលពេលកំណត់ត្រូវអនុវត្តសិទ្ធិទាមទារធ្វើឡើងដោយដើមចោទ បានមកដល់មុនពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ក្នុងការវិនិច្ឆ័យទៅលើអង្គហេតុ។

ឧទាហរណ៍ៈ ទាមទារឲ្យតុលាការចេញសាលក្រមបង្គាប់ឲ្យចុងចម្លើយសងប្រាក់កម្ចីដែលដល់ពេលកំណត់ត្រូវសង ឬ កំណត់ពេលត្រូវសងបានកន្លងផុត។

បណ្តឹងទាមទារឲ្យផ្តល់តាវកាលិកនាពេលបច្ចុប្បន្នមានច្រើនប្រភេទដូចជាៈ

---

[24] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១៦២

**ក. ការទាមទារប្រាក់ជាក់លាក់**

ករណីទី១៖ ដើមចោទ X ទាមទារឲ្យចុងចម្លើយ Y សងប្រាក់កម្ចីចំនួន ១០.០០០ ដុល្លារ ដោយផ្អែកលើកិច្ចសន្យាខ្ចីបរិភោគដែលបានបង្កើតឡើងកាលពីថ្ងៃទី០១ ខែ មិនា ឆ្នាំ ២០១៧ ហើយទាមទារឲ្យតុលាការចេញសាលក្រមបង្គាប់ឲ្យ ចុងចម្លើយ Y សងប្រាក់នោះ។

ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ៖ បង្គាប់ឲ្យចុងចម្លើយ Y សងប្រាក់ចំនួន ១០.០០០ ដុល្លារ ឲ្យទៅដើមចោទ X ។

**ខ. ការទាមទារឲ្យចាកចេញ និងប្រគល់អចលនវត្ថុជាក់លាក់ (ដី ឬ ផ្ទះ)**

ករណីទី២៖ X បានសង់ផ្ទះមួយនៅលើដី (A) ដែលជាកម្មសិទ្ធិរបស់ Y ដោយពុំមានការអនុញ្ញាតពី Y ។ Y ចង់ដាក់ពាក្យបណ្ដឹងទាមទារឲ្យ X រុះរើផ្ទះចេញពីដីរបស់ខ្លួន។

ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ៖ បង្គាប់ឲ្យចុងចម្លើយ X ចាកចេញ និងប្រគល់ដី (A) ដូចមានចែងក្នុងឧបសម្ព័ន្ធកម្មវត្ថុទៅឲ្យដើមចោទ Y។

**គ. ការទាមទារឲ្យប្រគល់ចនវត្ថុកំណត់មួយជាក់លាក់**

ករណីទី៣៖ X បានទិញរថយន្តមួយគ្រឿងពី Y ប៉ុន្តែ Y មិនបានប្រគល់រថយន្តនោះមកឲ្យ X នោះទេ។ X ចង់ដាក់ពាក្យបណ្ដឹងទាមទារឲ្យប្រគល់រថយន្តនោះមកឲ្យខ្លួន។

ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ៖ បង្គាប់ឲ្យចុងចម្លើយ Y ប្រគល់រថយន្តទៅឲ្យដើមចោទ X (ត្រូវធ្វើការបញ្ជាក់អំពីអត្តសញ្ញាណនៃរថយន្តដូចជា លេខចុះបញ្ជី ពណ៌ ប្រភេទ ឆ្នាំផលិត ស៊េរី ជាដើម)។

**ឃ. ការទាមទារឲ្យចុះបញ្ជីផ្ទេរកម្មសិទ្ធិដី**

ករណីទី៤៖ X បានទិញដី (A) មួយកន្លែងពី Y នៅថ្ងៃទី ០១ កក្កដា ឆ្នាំ ២០១២ ប៉ុន្តែ Y មិនបានធ្វើការសហការធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិលើដី (A) នោះទេ។ ដូច្នេះ X ចង់ដាក់ពាក្យបណ្ដឹងទាមទារឲ្យចុះបញ្ជីផ្ទេរកម្មសិទ្ធិដី។

ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ៖ បង្គាប់ឲ្យចុងចម្លើយ Y ធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូលដែលពាក់ព័ន្ធនឹងដី (A) ដូចមានបញ្ជាក់ក្នុងឧបសម្ព័ន្ធកម្មវត្ថុទៅឲ្យដើមចោទ X ដោយផ្អែកលើកិច្ចសន្យាទិញលក់ដី ដែលបានធ្វើកាលពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១២។

**ង. ការទាមទារឲ្យលុបចោលការចុះបញ្ជីផ្ទេរកម្មសិទ្ធិដី**

ករណីទី៥៖ X បានលក់ដី (A) មួយកន្លែងទៅឲ្យ Y និងបានផ្ទេរការចុះបញ្ជីកម្មសិទ្ធិដី (A) ទាំងមូលពី X ទៅឲ្យ Y រួចរាល់ហើយ។ តែក្រោយមក X បានលុបចោលកិច្ចសន្យាទិញ លក់ដីចុះថ្ងៃទី០១ ខែ កក្កដា ឆ្នាំ ២០១២ និងដាក់ពាក្យបណ្ដឹងទាមទារឲ្យលុបចោលការចុះបញ្ជីរបស់ Y។

ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ៖ បង្គាប់ឲ្យចុងចម្លើយ Y ធ្វើនីតិវិធីលុបចោលការចុះបញ្ជីផ្ទេរកម្មសិទ្ធិដី (A) ទៅឲ្យដើមចោទ X ដោយផ្អែកលើមូលហេតុនៃការលុបចោលកិច្ចសន្យាទិញ លក់ដី ចុះថ្ងៃទី០១ ខែ កក្កដា ឆ្នាំ ២០១២។

### ២.១.២. បណ្តឹងទាមទារឲ្យផ្តល់តាវកាលិកនាពេលអនាគត

បណ្តឹងទាមទារឲ្យផ្តល់តាវកាលិកនាពេលអនាគត សំដៅលើបណ្តឹងទាមទារឲ្យផ្តល់តាវកាលិកដែលដើមចោទបានធ្វើឡើងដោយមានការអះអាងអំពីសិទ្ធិទាមទារឲ្យផ្តល់តាវកាលិកមួយដែលពេលកំណត់ត្រូវអនុវត្តនោះមិនទាន់បានមកដល់នៅឡើយ។ ការទាមទារឲ្យផ្តល់តាវកាលិកនាពេលអនាគត គេអាចដាក់ពាក្យបណ្តឹងបានតែក្នុងករណីដែលមានភាពចាំបាច់ក្នុងការទាមទារបែបនេះជាមុនតែប៉ុណ្ណោះ[25]។

ជាធម្មតា ភាពចាំបាច់ត្រូវបានគេទទួលស្គាល់នៅពេលមានមូលហេតុដែលរំពឹងទុកថា កូនបំណុលនឹងមិនអនុវត្តកាតព្វកិច្ចនៅថ្ងៃកំណត់សង ដូចជាករណីដែលកូនបំណុលបានបដិសេធនឹងអត្ថិភាពនៃកាតព្វកិច្ចរបស់ខ្លួនមុនពេលដល់ថ្ងៃកំណត់សង ឬ ករណីដែលកូនបំណុលមិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួនមួយផ្នែក មុនពេលដែលផ្នែកផ្សេងទៀតនៃកាតព្វកិច្ចដល់កំណត់សង។ ភាពចាំបាច់ត្រូវទទួលស្គាល់ផងដែរ ក្នុងករណីដែលការខូចខាតរបស់ម្ចាស់បំណុលមិនអាចជួសជុលបាន ប្រសិនបើពុំមានការសងនៅពេលដល់ថ្ងៃកំណត់សងបានមកដល់ ដូចជា: ករណីបង់អាហារកាតព្វកិច្ច ឬ បង់សោហ៊ុយចាំបាច់សម្រាប់ចិញ្ចឹមកូន។

ឧទាហរណ៍៖ ក្នុងពេលស្ថិតក្នុងចំណងអាពាហ៍ពិពាហ៍ X និង Y បានបង្កើតបានកូនស្រីម្នាក់។ ក្រោយមក X និង Y បានលែងលះគ្នា។ Y បានព្រមព្រៀងជាមួយ X បង់ប្រាក់ចំនួន ២៥០ ដុល្លារជារៀងរាល់ចុងខែ ជាសោហ៊ុចាំបាច់ដើម្បីថែរក្សាកូន។ ប៉ុន្តែ ក្រោយមក Y មិនបានបង់ប្រាក់នោះទៀតទេ។ X ចង់ដាក់ពាក្យបណ្តឹងទាមទារសោហ៊ុយចាំបាច់ដើម្បីថែរក្សាកូន ចាប់ពីខែនេះ (ខែ កក្កដា ឆ្នាំ ២០១៧) រហូតដល់ពេលដែលកូនក្លាយជានីតិភាព (ខែ កក្កដា ឆ្នាំ ២០២២)។

ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ៖ បង្គាប់ឲ្យចុងចម្លើយ Y បង់ប្រាក់ចំនួន ២៥០ ដុល្លារ នៅរៀងរាល់ចុងខែនីមួយៗចាប់ពីខែ កក្កដា ឆ្នាំ ២០១៧ រហូតដល់ខែ កក្កដា ឆ្នាំ ២០២២ ទៅឲ្យដើមចោទ X ។

### ២.១.៣. សាលក្រមនៃបណ្តឹងទាមទារឲ្យផ្តល់តាវកាលិក

ប្រសិនបើតុលាការទទួលស្គាល់នូវអត្ថិភាពនៃសិទ្ធិទាមទារតាមរយៈការអះអាងរបស់ដើមចោទ នោះតុលាការត្រូវចេញសាលក្រមបង្គាប់ឲ្យចុងចម្លើយផ្តល់តាវកាលិកដែលមានខ្លឹមសារកំណត់មួយ

[25] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៧៦

ជាក់លាក់ ដូចជា បង់ប្រាក់ ឬ ប្រគល់អចលនវត្ថុ ឬ ហាមឃាត់មិនឲ្យធ្វើសកម្មភាពណាមួយដែលច្បាប់កំណត់ ជាដើម។ សាលក្រមប្រភេទនេះ គេហៅថា "**សាលក្រមបង្គាប់ឲ្យផ្តល់តាវកាលិក**"។

នៅពេលដែលសាលក្រមមានអានុភាពកំណត់ជាស្ថាពរអំពីអត្ថិភាពនៃសិទ្ធទាមទាររបស់ភាគីចំពោះតាវកាលិកនោះ ដែលត្រូវបានគេឲ្យឈ្មោះថា **អាជ្ញាអស់ជំនុំសារធាតុ**[26] ហើយមានអានុភាពអនុវត្ត។ មានន័យថា ដើមចោទអាចសម្រេចនូវសិទ្ធិដែលត្រូវបានទទួលស្គាល់ដោយសាលក្រមតាមការអនុវត្តដោយបង្ខំដោយផ្អែកលើសាលក្រមនោះ។ ជាធម្មតា លិខិតដែលទទួលស្គាល់នូវអានុភាពអនុវត្តក្នុងអត្ថន័យនេះ គេហៅថា **លិខិតអនុវត្ត**[27] ។

ផ្ទុយទៅវិញ ក្នុងករណីដែលតុលាការមិនទទួលស្គាល់នូវការទាមទាររបស់ដើមចោទទេនោះ តុលាការត្រូវចេញសាលក្រមដែលមានខ្លឹមសារថា "ច្រានចោលការទាមទាររបស់ដើមចោទ" ហើយសាលក្រមប្រភេទនេះ ក៏មាន "អាជ្ញាអស់ជំនុំសារធាតុ" ផងដែរ។ សាលក្រមនេះកំណត់ជាស្ថាពរនូវនត្ថិភាពនៃសិទ្ធិទាមទារឲ្យផ្តល់តាវកាលិកដែលអះអាងដោយដើមចោទ។

### ក. ការអនុវត្តសាលក្រមនៃបណ្តឹងទាមទារឲ្យផ្តល់តាវកាលិកនាពេលបច្ចុប្បន្ន

ក្នុងករណីភាគីដើមចោទឈ្នះក្តី ភាគីដើមចោទត្រូវយកសាលក្រមបង្គាប់ឲ្យផ្តល់តាវកាលិកដែលមានខ្លឹមសារកំណត់មួយជាក់លាក់ ដូចជា បង្គាប់ឲ្យបង់ប្រាក់ ឬ ប្រគល់អចលនវត្ថុ ឬ ហាមឃាត់មិនឲ្យធ្វើសកម្មភាពណាមួយដែលច្បាប់កំណត់ ជាអាទិ៍ ទៅឲ្យចុងចម្លើយ។ ប្រសិនបើចុងចម្លើយមិនព្រមអនុវត្តតាម នោះនីតិវិធីអនុវត្តដោយបង្ខំនឹងត្រូវបានយកមកអនុវត្ត។

### ខ. ការអនុវត្តសាលក្រមនៃបណ្តឹងទាមទារឲ្យផ្តល់តាវកាលិកនាពេលអនាគត

ប្រសិនបើសាលក្រមនៃបណ្តឹងទាមទារឲ្យផ្តល់តាវកាលិកនាពេលអនាគត មានភ្ជាប់ជាមួយនឹងលក្ខខណ្ឌ ឬ ពេលកំណត់មិនពិតប្រាកដ នោះដើមចោទអាចទទួលនូវរូបមន្តអនុវត្ត លុះត្រាតែគាត់បានបញ្ជាក់អំពីការបំពេញនូវលក្ខខណ្ឌ ឬ ការមកដល់នូវកំណត់ពេលមិនពិតប្រាកដនោះ[28]។ ប៉ុន្តែ ប្រសិនបើសាលក្រមនៃបណ្តឹងទាមទារឲ្យផ្តល់តាវកាលិកនាពេលអនាគត មានភ្ជាប់ជាមួយនឹងពេលកំណត់ពិតប្រាកដ នោះដើមចោទអាចទទួលនូវរូបមន្តអនុវត្តបានមុនពេលកំណត់ពិតប្រាកដនោះបានមកដល់ ប៉ុន្តែអាចចាប់ផ្តើមនីតិវិធីនៃការអនុវត្តដោយបង្ខំបានតែនៅក្រោយពេលកំណត់ពិតប្រាកដនោះបានមកដល់[29]។

---

[26] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១៩៤ កថាខណ្ឌទី ២

[27] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៣៥០ កថាខណ្ឌទី ២ ចំណុច ក និង ខ

[28] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៣៥៦ កថាខណ្ឌទី ១

[29] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៣៦១ កថាខណ្ឌទី ១

### ២.២. បណ្ដឹងទាមទារឲ្យបញ្ជាក់

បណ្ដឹងទាមទារឲ្យបញ្ជាក់ គឺជាបណ្ដឹងមួយប្រភេទដែលដើមចោទទាមទារឲ្យតុលាការចេញសាលក្រមបញ្ជាក់នូវអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដោយផ្អែកលើការអះអាងរបស់ដើមចោទនូវសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តមួយកំណត់ជាក់លាក់នៅក្នុងពាក្យបណ្ដឹង។

បណ្ដឹងទាមទារឲ្យបញ្ជាក់ដែលមានគោលបំណងអះអាងនូវអត្ថិភាពនៃសិទ្ធិ ជាអាទិ៍ ហៅថា "បណ្ដឹងទាមទារឲ្យបញ្ជាក់ដោយសកម្ម" រីឯបណ្ដឹងដែលអះអាងនូវនត្ថិភាពនៃសិទ្ធិ ហៅថា "បណ្ដឹងទាមទារឲ្យបញ្ជាក់ដោយអកម្ម"។

#### ក. បណ្ដឹងទាមទារឲ្យបញ្ជាក់ដោយសកម្ម

បណ្ដឹងទាមទារឲ្យបញ្ជាក់ដោយសកម្ម សំដៅលើបណ្ដឹងដែលបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនៅតែបន្តមានអត្ថិភាពដោយផ្សារភ្ជាប់ជាមួយនឹងសិទ្ធិ ឬទំនាក់ទំនងគតិយុត្តនោះ។

ឧទាហរណ៍:

ករណីទី១៖ X បានជួលដី (A) មួយកន្លែងពី Y នៅថ្ងៃទី០១ ខែ មេសា ឆ្នាំ ២០១៥ ហើយបានរស់នៅលើដីនោះតាំងពីពេលនោះមក។ ក្រោយមក Y ចង់បណ្ដេញ X ចេញពីដីនោះ និងបានផ្ញើរលិខិតជូនដំណឹងជាច្រើនដងទៅ X ដោយបង្គាប់ឲ្យរើចេញពីដីនោះ។ X ចង់រស់នៅបន្ត និងចង់ដាក់ពាក្យបណ្ដឹងទាមទារឲ្យបញ្ជាក់ពីអត្ថិភាពនៃសិទ្ធិជួលរបស់ខ្លួន។

ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ៖ បញ្ជាក់ថា សិទ្ធិជួលដោយផ្អែកលើភតិសន្យាដែលដើមចោទ X (ភតិក:) និងចុងចម្លើយ Y (ភតិបតី) ព្រមព្រៀងគ្នា ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៥ មានអត្ថិភាពលើដី (A)។

#### ខ. បណ្ដឹងទាមទារឲ្យបញ្ជាក់ដោយអកម្ម

បណ្ដឹងទាមទារឲ្យបញ្ជាក់ដោយអកម្ម សំដៅលើបណ្ដឹងដែលបញ្ជាក់អំពីនត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត ឬ កាតព្វកិច្ចដែលមិនមានអត្ថិភាពបន្ត។

ឧទាហរណ៍:

ករណីទី២៖ X បានខ្ចីប្រាក់ចំនួន ១០.០០០ ដុល្លារ ពី Y តាមរយៈកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី ០១ មេសា ឆ្នាំ២០១៥។ X បានសងប្រាក់គ្រប់ចំនួន តែ Y នៅតែទាមទារឲ្យ X សងប្រាក់។ X ចង់ដាក់ពាក្យបណ្ដឹងទាមទារឲ្យបញ្ជាក់អំពីនត្ថិភាពនៃកាតព្វកិច្ចរបស់ខ្លួន។

ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ៖ បញ្ជាក់ថា កាតព្វកិច្ចបង់ប្រាក់របស់ដើមចោទ X ចំនួន ១០.០០០ ដុល្លារ និងការប្រាក់យឺតយ៉ាវ ទៅឲ្យចុងចម្លើយ Y ដោយផ្អែក

លើកិច្ចសន្យាខ្ចីបរិភោគរវាងដើមចោទ X និងចុងចម្លើយ Y ចុះថ្ងៃទី០១ ខែ មេសា ឆ្នាំ ២០១៥ មិនមានអត្ថិភាពទេ។

### ២.២.១. កម្មវត្ថុនៃបណ្ដឹងទាមទារឲ្យបញ្ជាក់

ជាគោលការណ៍ កម្មវត្ថុនៃបណ្ដឹងទាមទារឲ្យបញ្ជាក់សំដៅតែទៅលើការបញ្ជាក់អំពី "អត្ថិភាព" ឬ "នត្ថិភាព" នៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលមានជាក់ស្ដែងតែប៉ុណ្ណោះ គឺមិនរាប់បញ្ចូលការផ្ដល់តាវកាលិកណាមួយនោះទេ។ បណ្ដឹងប្រភេទនេះ ជាគោលការណ៍ គឺមិនអនុញ្ញាតឲ្យធ្វើការទាមទារឲ្យបញ្ជាក់នូវអត្ថិភាព ឬ នត្ថិភាពនៃអង្គហេតុនោះទេ។ ប៉ុន្តែមានករណីពិសេស គឺអាចមានការអនុញ្ញាតឲ្យធ្វើបណ្ដឹងទាមទារឲ្យបញ្ជាក់នូវភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃឯកសារដែលបញ្ជាក់អំពីទំនាក់ទំនងគតិយុត្ត។ ភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃឯកសារ សំដៅលើការបង្កើត តើវាបានបង្កើតឡើងដោយផ្អែកលើឆន្ទៈរបស់បុគ្គលដែលបានធ្វើលិខិតពិតមែន ឬ ទេ។ ភាពត្រឹមត្រូវនៃលិខិតនោះ គឺជាអង្គហេតុ ក៏ប៉ុន្តែអាចអនុញ្ញាតពិសេសឲ្យធ្វើបណ្ដឹងទាមទារឲ្យបញ្ជាក់អំពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃឯកសារដែលបញ្ជាក់អំពីទំនាក់ទំនងគតិយុត្តនោះ ដោយសារតែ ប្រសិនបើភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃការបង្កើតកិច្ចសន្យា ជាអាទិ៍ ត្រូវបានចូលជាស្ថាពរតាមរយៈសាលក្រមរវាងភាគីនឹងអស់វិវាទ។

ឧបមាថា ដើមចោទដាក់ពាក្យបណ្ដឹងទៅតុលាការដើម្បីធ្វើការបញ្ជាក់អង្គហេតុថា "X បានសាងសង់អគារ" ឬក៏ បញ្ជាក់ថា "Y បានធ្វើឲ្យខូចខាតរថយន្តរបស់ខ្លួន" នោះបណ្ដឹងទាមទារឲ្យបញ្ជាក់របៀបនេះនឹងត្រូវតុលាការលើកចោល ដោយសារមូលហេតុថា ខ្វះផលប្រយោជន៍នៃបណ្ដឹង[30] ពីព្រោះថា ខ្លឹមសារនៃការទាមទាររបស់ដើមចោទ គឺដើម្បីបញ្ជាក់អំពីអង្គហេតុតែប៉ុណ្ណោះ។

បណ្ដឹងទាមទារឲ្យបញ្ជាក់ គឺគេកម្រិតការទាមទារឲ្យបញ្ជាក់អំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិនាពេលបច្ចុប្បន្ន ហើយជាគោលការណ៍គេមិនទទួលស្គាល់ឲ្យធ្វើបណ្ដឹងទាមទារឲ្យបញ្ជាក់អំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តអតីតកាល ឬ អនាគតកាលឡើយ។ ករណីហាមឃាត់បែបនេះ ដោយហេតុថា ទោះបីជាទំនាក់ទំនងគតិយុត្តក្នុងពេលអតីតកាលត្រូវបានបញ្ជាក់ដោយសាលក្រមដែលបានចូលជាស្ថាពរក៏ដោយ ក៏ស្ថានភាពនៃទំនាក់ទំនងគតិយុត្តនោះ អាចត្រូវបានផ្លាស់ប្ដូរនាពេលបច្ចុប្បន្ន ឬ ទោះបីជាទំនាក់ទំនងគតិយុត្តនាពេលអនាគតត្រូវបានបញ្ជាក់ដោយសាលក្រមស្ថាពរក៏ដោយ ក៏ទំនាក់ទំនងនោះអាចនឹងប្រែប្រួលមុនពេលកាលបរិច្ឆេទនាពេលអនាគតនោះមកដល់។ ហេតុដូច្នេះសាលក្រមនេះ មិនអាចដោះស្រាយវិវាទដែលកំពុងកើតមាននាពេលបច្ចុប្បន្នបានឡើយ។

[30] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៧៤

ឧទាហរណ៍៖ X បានលក់រថយន្តរបស់ខ្លួនឲ្យទៅ Y។ ក្រោយមក X បានលុបចោលកិច្ចសន្យាទិញលក់រថយន្តចោល។ Y បានទាមទារឲ្យប្រគល់រថយន្តនោះមកឲ្យខ្លួន ប៉ុន្តែ X បានបដិសេធការអនុវត្តកាតព្វកិច្ចប្រគល់រថយន្ត ដោយមូលហេតុ ការលុបចោលកិច្ចសន្យា។ X បានដាក់ពាក្យបណ្ដឹងដើម្បីបញ្ជាក់អំពីការលុបចោលនៃកិច្ចសន្យា។

បណ្ដឹងខាងលើនេះ គឺពុំបានបង្ហាញពីផលប្រយោជន៍នៃបណ្ដឹងនោះឡើយ ពីព្រោះបណ្ដឹងនេះ គឺជាបណ្ដឹងទាមទារឲ្យបញ្ជាក់អំពីទំនាក់ទំនងគតិយុត្តនាពេលអតីតកាលដែលមិនអាចដោះ-ស្រាយវិវាទរវាង X និង Y បានឡើយ។ ហេតុនេះ ការទាមទារនឹងត្រូវបានច្រានចោល។ មួយវិញទៀត តើនឹងមានអ្វីកើតឡើង ប្រសិនបើបណ្ដឹងខាងលើនេះត្រូវបានទទួលយកដោយមានកំហុសរបស់តុលាការ?

ក្នុងករណីនេះ ប្រសិនបើ X ឈ្នះក្ដី នោះសាលក្រមនឹងកំណត់អំពីការលុបចោលនៃកិច្ចសន្យាដែលសាលក្រមអាចនឹងដោះស្រាយវិវាទខាងលើនេះបាន។ ក៏ប៉ុន្តែ ប្រសិនបើ X ចាញ់ក្ដីវិញ នោះមានន័យថា សេចក្ដីសម្រេចក្នុងសាលក្រមនឹងកំណត់ពីសុពលភាពនៃកិច្ចសន្យាទៅវិញ ប៉ុន្តែពុំបានកំណត់ពីអត្ថិភាពនៃកាតព្វកិច្ចរបស់ X ឡើយ។ ដូច្នេះ ទោះបីជាមានសាលក្រមហើយក៏ដោយ X នៅតែអាចអះអាងថាខ្លួនគ្មានកាតព្វកិច្ចនោះទេ។ X អាចនិយាយថា "**យល់ព្រម ខ្ញុំទទួលស្គាល់ថាកិច្ចសន្យានេះមានសុពលភាព ប៉ុន្តែ កាតព្វកិច្ចរបស់ខ្ញុំត្រូវបានលើកលែង ឬក៏ ផុតរលត់អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលទៅហើយ**"។ ម្យ៉ាងវិញទៀត X ក៏អាចនឹងធ្វើបណ្ដឹងទីពីរទៅតុលាការដើម្បីបញ្ជាក់អំពីនត្ថិភាពនៃកាតព្វកិច្ចរបស់ខ្លួនផងដែរ។

បណ្ដឹងទាមទារឲ្យបញ្ជាក់ពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តអតីតកាល ឬ អនាគតកាលក៏អាចធ្វើបានដែរ ប្រសិនបើមានករណីលើកលែងពិសេសដែលមានភាពចាំបាច់ ហើយសមស្របដើម្បីដោះស្រាយវិវាទតាមផ្លូវច្បាប់ដែលកំពុងកើតមានក្នុងពេលបច្ចុប្បន្ននេះ។

ដោយហេតុថា បណ្ដឹងទាមទារឲ្យបញ្ជាក់មានគោលបំណងការពារផលប្រយោជន៍របស់គូភាគីក្នុងគោលបំណងដើម្បីដោះស្រាយវិវាទដែលកើតចេញពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តជាក់លាក់ណាមួយ[31]។ ហេតុដូច្នេះហើយ បណ្ដឹងប្រភេទនេះមិនអនុញ្ញាតឲ្យធ្វើការទាមទារឲ្យបញ្ជាក់ការបកស្រាយអំពីសុពលភាព ឬ មោឃភាពនៃច្បាប់ណាមួយបានឡើយ។ ដូចជា មិនអនុញ្ញាតឲ្យដាក់ពាក្យបណ្ដឹងទាមទារឲ្យបញ្ជាក់ពីមោឃភាពនៃបញ្ញត្តិនៃព្រះរាជក្រឹត្យណាមួយ ដោយអះអាងថាបញ្ញត្តិនោះមានភាពផ្ទុយនឹងបទបញ្ញត្តិនៃច្បាប់ណាមួយនោះទេ។

[31] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៧៤

### ២.២.២. សាលក្រមនៃបណ្តឹងទាមទារឲ្យបញ្ជាក់

ប្រសិនបើតុលាការទទួលស្គាល់ថាការទាមតាររបស់ដើមចោទត្រឹមត្រូវ នោះតុលាការត្រូវចេញសាលក្រមដែលមានខ្លឹមសារបញ្ជាក់អំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលទាមទារដោយដើមចោទ។ សាលក្រមនេះត្រូវបានគេហៅថា "**សាលក្រមបញ្ជាក់**"។ ផ្ទុយទៅវិញ ប្រសិនបើតុលាការមិនទទួលស្គាល់នូវភាពត្រឹមត្រូវនៃការទាមទារទេ តុលាការត្រូវចេញសាលក្រមច្រានចោលនូវការទាមទាររបស់ដើមចោទ។ សាលក្រមប្រភេទនេះត្រូវបានគេហៅថា "**សាលក្រមចុងក្រោយ**"។

សាលក្រមបញ្ជាក់មានអានុភាពទៅលើការវិនិច្ឆ័យអំពីសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តណាមួយដែលមាននៅក្នុងខ្លឹមសារនៃសាលក្រមនោះ។ សិទ្ធិជាក់លាក់នេះមិនអាចយកមកវិនិច្ឆ័យម្តងទៀតបានឡើយ ពីព្រោះថា វាជាអាជ្ញាអស់ជំនុំសារធាតុ ហើយមានអានុភាពជាស្ថាពរ។ ចំពោះសាលក្រមដែលធ្វើការច្រានចោលការទាមទារឲ្យបញ្ជាក់ ក៏កើតមាននូវអានុភាពជាអាជ្ញាអស់ជំនុំសារធាតុផងដែរ។

សាលក្រមច្រានចោលការទាមទារក្នុងបណ្តឹងទាមទារឲ្យបញ្ជាក់នេះ នឹងមានអានុភាពជាអាជ្ញាអស់ជំនុំសារធាតុចំពោះការវិនិច្ឆ័យថា "កាតព្វកិច្ចដែលដើមចោទបានអះអាងថាពុំមាននោះមានអត្ថិភាព"។ ចំពោះចុងចម្លើយ សាលក្រមនេះគឺជាសាលក្រមបញ្ជាក់ជាស្ថាពរនូវអត្ថិភាពនៃសិទ្ធិលើបំណុល (សិទ្ធិទាមទារ) ក៏ប៉ុន្តែ នេះក៏ជាសាលក្រមបញ្ជាក់ហើយពុំមានអានុភាពអនុវត្តទេ ហេតុដូចនេះហើយ វាមិនអាចក្លាយទៅជាលិខិតអនុវត្ត[32] ដើម្បីសម្រេចសិទ្ធិលើបំណុលដែលត្រូវបានទទួលស្គាល់ក្នុងសាលក្រមនោះឡើយ។

### ៣.៣. បណ្តឹងទាមទារឲ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត

បណ្តឹងទាមទារឲ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត គឺជាបណ្តឹងទាមទារឲ្យតុលាការចេញសាលក្រមប្រកាសបង្កើតជាថ្មី ឬ ផ្លាស់ប្តូរ ឬ បញ្ចប់នូវទំនាក់ទំនងគតិយុត្តដោយផ្អែកលើការអះអាងអំពីអត្ថិភាពនៃសិទ្ធិបង្កើត ឬ អំពីមូលហេតុនៃការបង្កើតទំនាក់ទំនងគតិយុត្តជាក់លាក់ដែលជាការទាមទារតាមផ្លូវបណ្តឹង។

ឧទាហរណ៍៖ បណ្តឹងលែងលះ។

បណ្តឹងលែងលះ គឺជាបណ្តឹងដែលមានគោលបំណងបញ្ចប់នូវទំនាក់ទំនងអាពាហ៍ពិពាហ៍ដែលជាទំនាក់ទំនងគតិយុត្តដែលបានបង្កើតពីមុនមករវាងប្តី និងប្រពន្ធ។

---
[32] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៣៥០ កថាខណ្ឌទី២ ចំណុច ក

ជាគោលការណ៍ ច្បាប់ទទួលស្គាល់នូវការបង្កើតទំនាក់ទំនងគតិយុត្តថ្មីដោយផ្អែកលើឆន្ទៈរបស់ភាគី។ ប៉ុន្តែមានករណីមួយចំនួនដែលការបង្ហាញឆន្ទៈរបស់ភាគី គឺមិនទាន់គ្រប់គ្រាន់ដើម្បីឲ្យអានុភាពនៃការបង្កើតទំនាក់ទំនងគតិយុត្តកើតមានឡើងនោះទេ ដែលចាំបាច់ត្រូវមានការទាមទារទៅតុលាការ ហើយតុលាការចេញសាលក្រមឆ្លើយតបទៅនឹងការទាមទារនោះ។

ឧទាហរណ៍៖ ការបង្កើតសុំកូន។

### ៣.៣.១. កម្មវត្ថុនៃបណ្តឹងទាមទារឲ្យបង្កើត ប្តូរ ឬ រំលត់នូវទំនាក់ទំនងគតិយុត្ត

ការទាមទារតាមផ្លូវបណ្តឹងនៃបណ្តឹងទាមទារឲ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្តត្រូវមានការអះអាងអំពីអត្ថិភាពនៃសិទ្ធិបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្តដែលបានកំណត់មួយ ដូចជា មូលហេតុនៃបណ្តឹងសុំឲ្យជំនុំជម្រះសាជាថ្មីទៅលើសាលក្រមស្ថាពរ ជាដើម។

ទោះបីបណ្តឹងដែលមានគោលបំណងទាមទារឲ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្តដូចគ្នាក៏ដោយ តែបើមិនបានអះអាងអំពីសិទ្ធិ និងមូលហេតុនៃការបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្តទេនោះ តុលាការក៏គ្មានមូលដ្ឋានតាមផ្លូវច្បាប់ណាមួយដើម្បីយកមកបង្កើតជាទំនាក់ទំនងគតិយុត្តនោះដែរ។ ដូច្នេះ បណ្តឹងបែបនេះមិនចាត់ចូលជាបណ្តឹងទាមទារឲ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្តដូចដែលបានរៀបរាប់មកពីខាងដើមនោះទេ។ បណ្តឹងបែបនេះ គេហៅថា "បណ្តឹងទាមទារឲ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្តតាមទម្រង់" ។ ឧទាហរណ៍៖ បណ្តឹងទាមទារឲ្យបែងចែកវត្ថុកម្មសិទ្ធិអវិភាគ[33]។

ម្យ៉ាងវិញទៀត សិទ្ធិបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្តដែលត្រូវអះអាងក្នុងបណ្តឹងទាមទារឲ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត មិនមានអានុភាពដោយសារតែការបង្ហាញឆន្ទៈរបស់ភាគីប៉ុណ្ណោះទេ ហេតុនេះហើយ គេអាចហៅថា សិទ្ធិបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្តដែលត្រូវអនុវត្តតែតាមផ្លូវតុលាការ។

### ៣.៣.២. សាលក្រមនៃបណ្តឹងទាមទារឲ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត

ប្រសិនបើតុលាការទទួលស្គាល់តាមការអះអាងរបស់ដើមចោទចំពោះការទាមទារ នោះតុលាការត្រូវចេញសាលក្រមកំណត់នូវទំនាក់ទំនងគតិយុត្តមួយយ៉ាងជាក់លាក់។ សាលក្រមនេះមានអានុភាពប្រតិសកម្ម ឬ មានអានុភាពឆ្ពោះទៅអនាគត។ អានុភាពទាំងនេះ វាអាស្រ័យទៅនឹងការកំណត់ដោយច្បាប់សារធាតុ ឬ តាមច្បាប់នីតិវិធីស្របតាមខ្លឹមសារនៃសាលក្រម។

សាលក្រមបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្តមានអានុភាពប្រតិសកម្មដូចជា សាលក្រមទទួលស្គាល់ឪពុក និងកូន មានអានុភាពប្រតិសកម្ម ហើយសាលក្រមខ្លះមានអានុភាពឆ្ពោះទៅ

[33] ក្រមរដ្ឋប្បវេណី មាត្រា ២១១

អនាគត ដូចជា សាលក្រមលែងលះ សាលក្រមលុបចោលអាពាហ៍ពិពាហ៍ ជាអាទិ៍។ ម្យ៉ាងទៀត ក្នុងករណីដែលតុលាការមិនទទួលស្គាល់តាមការទាមទាររបស់ដើមចោទទេនោះ តុលាការត្រូវចេញសាលក្រមច្រានចោលនូវការទាមទាររបស់ដើមចោទ។ សាលក្រមច្រានចោលបែបនេះមិនមានអានុភាពដើម្បីបង្កើតទំនាក់ទំនងគតិយុត្តនោះទេ វាមានអានុភាពជាអាជ្ញាអស់ជំនុំសារធាតុរវាងភាគី។

# ជំពូកទី២

# អង្គហេតុដែលជាមូលហេតុនៃការទាមទារ ឬ អង្គហេតុចម្បង

អង្គហេតុចម្បង គឺជាអង្គហេតុមួយដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការបញ្ជាក់អំពី អត្ថិភាព ឬនត្ថិភាពនៃសិទ្ធិដែលគូភាគីបានអះអាងនៅក្នុងការថ្លែងការណ៍របស់ខ្លួន។ ជាទូទៅ អង្គហេតុចម្បងបានដើរនាទីយ៉ាងសំខាន់ដែលអាចឲ្យតុលាការធ្វើការពិចារណាដោយផ្អែកទៅលើភស្តុតាងលើអង្គហេតុនោះ ថាតើអង្គហេតុនោះបានបញ្ជាក់អំពីសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលភាគីបានអះអាងដែរឬទេ ដើម្បីអាចឲ្យតុលាការទទួលស្គាល់នូវអង្គហេតុដែលគូភាគីបានលើកឡើងនោះ[34]។ នៅរាល់ពេលដែលដើមចោទ ឬ ចុងចម្លើយ បានលើកឡើងអំពីអង្គហេតុចម្បង ដែលភាគីណាមួយនឹងត្រូវទទួលបន្ទុកក្នុងការបញ្ជាក់ភស្តុតាងផ្សេងៗដើម្បីបញ្ជាក់ឲ្យកាន់តែច្បាស់លាស់អំពីសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តរបស់ខ្លួន។

## ផ្នែកទី១. ទ្រឹស្តី និង ការបែងចែកអង្គហេតុចម្បង

គោលបំណងនៃបណ្ដឹងរដ្ឋប្បវេណី គឺដើម្បីរក្សាការពារសិទ្ធិដែលចែងដោយច្បាប់សារធាតុ ដូច្នេះកម្មវត្ថុនៃការវិនិច្ឆ័យក្នុងនីតិវិធីបណ្ដឹង គឺជាសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលស្ថិតក្រោមច្បាប់សារធាតុ។ នៅក្នុងបណ្ដឹងរដ្ឋប្បវេណី តុលាការត្រូវសម្រេចថាតើបណ្ដឹងទាមទារនោះ មាន ឬ គ្មានមូលហេតុត្រឹមត្រូវ។ មានន័យថា ដើមចោទ មាន ឬ គ្មានសិទ្ធិ ហើយសិទ្ធិទាមទាររបស់ដើមចោទ គឺជាចំណុចដែលតុលាការមិនអាចយល់ដឹងផ្ទាល់បានទេ ពីព្រោះសិទ្ធិជាទស្សនវិស័យអរូបីដែលមិនអាចប៉ះ ឬ មើលឃើញដោយភ្នែកបាន។ ហេតុដូច្នេះហើយ ដើម្បីវិនិច្ឆ័យអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ តុលាការត្រូវវិនិច្ឆ័យអំពីអត្ថិភាព ឬ នត្ថិភាពនៃអង្គហេតុដែលកើតមានឡើងនូវសិទ្ធិនោះ ដោយហេតុថា អង្គហេតុគឺជាចំណុចដែលអាចយល់ដឹងអំពីអត្ថិភាព ឬ នត្ថិភាពបានដោយភស្តុតាង។

ឧទាហរណ៍៖ X បានដាក់ពាក្យបណ្ដឹងទាមទារឲ្យ Y បញ្ជាក់កម្មសិទ្ធិនៃកង់ដែលគាត់បានកាន់កាប់។ នៅក្នុងបណ្ដឹងទាមទារឲ្យបញ្ជាក់នូវកម្មសិទ្ធិរបស់ X កង់ជាវត្ថុដែលអាចប៉ះបាន ឬ មើលបាន ប៉ុន្តែ កម្មសិទ្ធិនៃកង់ គឺជាទស្សនៈវិស័យអរូបី យើងមិនអាចយល់ដឹងថា អ្នកណាជាកម្មសិទ្ធិករឡើយ។ ប្រសិនបើ X បានទិញកង់នោះនៅផ្សារ ដើម្បីបញ្ជាក់កម្មសិទ្ធិ តុលាការអាចតម្រូវឲ្យកម្មសិទ្ធិករអះអាងនូវអង្គហេតុដែលកើតឡើងនូវសិទ្ធិដូចជា បានទិញនៅពេលណា? បានទិញពីនរណា? ទិញដោយតម្លៃប៉ុន្មាន? ដោយភ្ជាប់មកជាមួយនូវភស្តុតាង ដូចជាកិច្ចសន្យាលក់ទិញ ឬ វិក័យបត្រ ជាអាទ៍។ តាមរយៈភស្តុតាងនេះ តុលាការអាចយល់ដឹងអំពីកិច្ចសន្យាលក់ទិញនោះ និងដឹងថា អ្នកណាជាកម្មសិទ្ធិករនៃកង់នោះ។

[34] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១២៣

អង្គហេតុដូចជា ការបង្កើតកិច្ចសន្យាលក់ ទិញនេះ គឺជាអង្គហេតុដែលជាមូលហេតុនៃការបង្កើតទំនាក់ទំនងតាមផ្លូវច្បាប់ដែលគេហៅថា **អង្គហេតុចម្បង**។ អង្គហេតុចម្បង គឺជាអង្គហេតុដែលបង្កើតឲ្យមាននូវអានុភាពតាមផ្លូវច្បាប់។ អង្គហេតុចម្បង ត្រូវបានបែងចែងជា ៤ (បួន) ប្រភេទ ដូចជា៖ អង្គហេតុនៃការកកើតឡើងនូវសិទ្ធិ អង្គហេតុរាំងសិទ្ធិ អង្គហេតុរំលត់សិទ្ធិ និងអង្គហេតុទប់ស្កាត់ (បដិសេធ) នៃសិទ្ធិ។

### ១.១. អង្គហេតុនៃការកកើតឡើងនូវសិទ្ធិ

អង្គហេតុនៃការកកើតឡើងនូវសិទ្ធិ សំដៅលើអង្គហេតុដែលជាមូលហេតុនៃការកើតឡើងនូវសិទ្ធិ រវាងទំនងទំនាក់បុគ្គលនៅក្នុងព្រឹត្តិការណ៍ឬ សកម្មភាពណាមួយ។

ឧទាហរណ៍៖ X ទាមទារឲ្យ Y បង់តម្លៃនៃកង់ដោយមូលហេតុ X និង Y បានបង្កើតកិច្ចសន្យាទិញលក់ កង់ជាមួយគ្នា (យោងតាមមាត្រា ៥១៥ មាត្រា ៥៥៤ និងមាត្រា៥៥៥ នៃក្រមរដ្ឋប្បវេណី)។

### ១.២. អង្គហេតុរាំងសិទ្ធិ

អង្គហេតុរាំងសិទ្ធិ សំដៅលើអង្គហេតុដែលជាមូលហេតុនៃការរាំងសិទ្ធិមិនឲ្យកើតមានដោយសារមានភាពមិនប្រក្រតីណាមួយកើតឡើងនៅក្នុងទំនាក់ទំនងគតិយុត្ត ហើយជាហេតុរាំងមិនឲ្យអនុវត្តសិទ្ធិបាន។

ឧទាហរណ៍៖ កិច្ចសន្យាកើតឡើងដោយវិការៈនៃការបង្ហាញឆន្ទៈ[35] កិច្ចសន្យាផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ[36] ជាអាទិ៍ ទោះបីជាកិច្ចសន្យាកើតមានក៏ដោយ ប៉ុន្តែមានអង្គហេតុផ្សេងរាំង ឬ ជាឧបសគ្គមិនឲ្យអានុភាពនោះបន្តបានទៀត។

### ១.៣. អង្គហេតុរំលត់សិទ្ធិ

អង្គហេតុរំលត់សិទ្ធិ សំដៅលើអង្គហេតុមួយ ដែលសិទ្ធិបានកើតឡើងរួចហើយ ប៉ុន្តែសិទ្ធិនោះត្រូវបានរលត់ទៅវិញដោយមូលហេតុ ឬ សកម្មភាពគតិយុត្តណាមួយ។

ឧទាហរណ៍៖ លោក X បានខ្ចីប្រាក់ពីលោក Y ចំនួន ១០០ ដុល្លារ តាមរយៈកិច្ចសន្យាខ្ចីបរិភោគ។ ហើយ លោក X ត្រូវសងប្រាក់ចំនួន ១០០ ដុល្លារនោះ នៅថ្ងៃទី ០១ ខែកក្កដា ឆ្នាំ ២០១៧។ នៅថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៧ លោក X បានសងប្រាក់ចំនួន ១០០ ដុល្លារឲ្យទៅលោក Y។ ក្នុងករណីនេះ សិទ្ធិលើបំណុលរបស់លោក Y ចំពោះលោក X ត្រូវបានរលត់ដោយសារការសង។ ដូច្នេះ លោក Y មិនអាចទាមទារឲ្យលោក X សងប្រាក់ចំនួន ១០០ ដុល្លារនោះម្តងទៀតបានទេ។

[35] ក្រមរដ្ឋប្បវេណី មាត្រា ៣៤៥

[36] ក្រមរដ្ឋប្បវេណី មាត្រា ៣៥៤

### ១.៤. អង្គហេតុទប់ស្កាត់ (បដិសេធ) សិទ្ធិ

អង្គហេតុទប់ស្កាត់សិទ្ធិ សំដៅលើអង្គហេតុដែលសិទ្ធិបានកើតមានហើយ ប៉ុន្តែមិនទាន់អាចអនុវត្តសិទ្ធិនោះបានដោយអង្គហេតុផ្សេង។ អង្គហេតុទប់ស្កាត់សិទ្ធិនេះ គេអាចហៅម្យ៉ាងទៀតថា អង្គហេតុបដិសេធសិទ្ធិ។

ឧទាហរណ៍៖ សិទ្ធិតវ៉ាឲ្យអនុវត្តព្រមគ្នា[37] ទោះបីជាម្ចាស់បំណុលមានសិទ្ធិហើយក៏ដោយ ក៏កូនបំណុលនៅតែអាចបដិសេធសិទ្ធិនោះបាន ដោយទាមទារឲ្យម្ចាស់បំណុលអនុវត្តនូវកាតព្វកិច្ចព្រមពេលជាមួយនឹងខ្លួនបានដែរ។

## ផ្នែកទី២. លំហូរនៃការបញ្ជាក់អង្គហេតុ

ដើម្បីអាចឲ្យតុលាការសម្រេចសេចក្ដីទៅតាមការទាមទាររបស់ខ្លួន ភាគីនីមួយៗត្រូវធ្វើនូវសកម្មភាពមួយចំនួននៅក្នុងនីតិវិធីនៃបណ្ដឹងរបស់ខ្លួន ដោយហេតុថា តុលាការនៃរឿងក្ដីរដ្ឋប្បវេណីគឺជាតុលាការអកម្ម។ មានន័យថា តុលាការមិនអាចយកអង្គហេតុណាដែលភាគីមិនបានអះអាងមកធ្វើជាមូលដ្ឋាននៃសាលក្រមបានឡើយ"[38]។

ម្យ៉ាងវិញទៀតតុលាការមិនអាចដឹងថា តើអង្គហេតុណាមួយជាអង្គហេតុពិតប្រាកដ ឬ ជាអង្គហេតុក្លែងក្លាយនោះទេ លុះត្រាតែគូភាគីលើកយកនូវភស្តុតាងមកបញ្ជាក់ឲ្យកាន់តែច្បាស់លាស់អំពីទំនាក់ទំនងរវាងភស្តុតាងទៅនឹងសិទ្ធិ និងផលប្រយោជន៍ចំពោះការទាមទាររបស់ខ្លួន។ ជាទូទៅតុលាការត្រូវទទួលស្គាល់អង្គហេតុដោយផ្អែកលើភស្តុតាងជាមូលដ្ឋាន ប៉ុន្តែតុលាការអាចពិចារណាអំពីស្ថានភាពទាំងមូលដែលបានលើកឡើងនៅពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់បាន។ អង្គហេតុដែលភាគីបានសារភាពនៅចំពោះមុខតុលាការ និងអង្គហេតុដែលតុលាការយល់ឃើញថាមានភាពជាក់ស្ដែង តុលាការអាចទទួលស្គាល់អង្គហេតុនោះបានដោយពុំចាំបាច់ផ្អែកលើភស្តុតាងនោះទេ[39]។

### ២.២ ការទាមទារ

#### ២.២.១. គោលគំនិតនៃការទាមទារ

គោលគំនិតនៃការទាមទារ គឺជាផ្នែកសន្និដ្ឋាននៃការអះអាងរបស់ដើមចោទនៅក្នុងបណ្ដឹង (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៧៥ កថាខណ្ឌទី២ ចំណុច ខ)។

[37] ក្រមរដ្ឋប្បវេណី មាត្រា ៥៥១ និងមាត្រា ៥៥៨

[38] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៩៥

[39] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១២៣

នៅក្នុងដំណាក់កាលដំបូងនៅក្នុងនីតិវិធីដែលភាគីត្រូវធ្វើ គឺការទាមទារ ដែលភាគីត្រូវធ្វើការអះអាងអំពីអត្ថិភាព ឬ នត្ថិភាព ឬ ទំនាក់ទំនងគតិយុត្តតាមផ្លូវច្បាប់សារធាតុដែលបានកំណត់។ ក្នុងការសរសេរពាក្យបណ្តឹងទាមទារទៅតុលាការ ភាគីត្រូវសរសេរចំណុចទាំងឡាយដែលខ្លួនចង់ទាមទារ ដើម្បីឲ្យតុលាការចេញសេចក្តីសម្រេចតាមការទាមទាររបស់ខ្លួន ដោយហេតុថា តុលាការអាចចេញសេចក្តីសម្រេចបាន លុះត្រាតែមានបណ្តឹងទាមទារពីគូភាគី។ ផ្ទុយទៅវិញ ប្រសិនបើភាគីមិនបានបញ្ជាក់ការទាមទារនៅក្នុងពាក្យបណ្តឹងរបស់ខ្លួនទេ បណ្តឹងនោះនឹងមានលក្ខណៈមិនគ្រប់គ្រាន់ដែលគ្មានផលប្រយោជន៍នៃបណ្តឹង ហើយជាហេតុដែលនាំឲ្យតុលាការលើកពាក្យបណ្តឹងចោលដោយមិនចាំបាច់ឆ្លងកាត់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់បាន។ ហេតុនេះហើយ ការទាមទារគឺជាចំណុចដ៏សំខាន់ដែលភាគីចាំបាច់ត្រូវធ្វើការបញ្ជាក់នៅក្នុងបណ្តឹង។

### ២.២.២. កម្មវត្ថុនៃបណ្តឹង

កម្មវត្ថុនៃបណ្តឹង គឺជាសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តកំណត់មួយដែលជាខ្លឹមសារនៃការទាមទារតាមផ្លូវបណ្តឹង (ការអះអាងរបស់ដើមចោទ)។

ឧទាហរណ៍៖ សិទ្ធិទាមទារឲ្យបង់ថ្លៃលក់ទិញ ដោយផ្អែកលើកិច្ចសន្យាលក់ទិញមួយ។

ជាទូទៅ បណ្តឹងរដ្ឋប្បវេណីមានគោលបំណងដោះស្រាយនូវរាល់វិវាទផ្នែករដ្ឋប្បវេណីដោយផ្អែកលើច្បាប់ទាក់ទងនៅនឹងសិទ្ធិរបស់បុគ្គលឯកជន។ ហេតុដូចនេះ វិវាទទាំងឡាយណាដែលមិនមែនជាកម្មវត្ថុនៃវិវាទតាមផ្លូវឯកជនជាក់ស្តែងទេនោះ តុលាការពុំអាចដោះស្រាយដោយសាលក្រមបានឡើយ ដូចជា វិវាទទាក់ទងនឹងការបកស្រាយទ្រឹស្តី ឬ ច្បាប់ណាមួយ ជាអាទិ៍។

### ២.២.៣. មូលហេតុនៃការទាមទារ

គ្រប់ការទាមទារទាំងអស់ សុទ្ធតែមានមូលហេតុគតិយុត្តដែលផ្សាភ្ជាប់គ្នារវាងសិទ្ធិនិងកាតព្វកិច្ច។ ឧទាហរណ៍៖ ករណីកិច្ចរបស់ភាគីអ្នកលក់ និងភាគីអ្នកទិញ ដែលមានចែងក្នុងបញ្ញត្តិមាត្រា ៥១៥ នៃក្រមរដ្ឋប្បវេណី " អ្នកមានករណីកិច្ចផ្ទេរកម្មសិទ្ធិ និងសិទ្ធិផ្សេងទៀតលើទ្រព្យសម្បត្តិឲ្យទៅភាគីម្ខាងទៀត ហៅថា អ្នកទិញ ហើយអ្នកទិញមានករណីកិច្ចត្រូវចេញថ្លៃជាប្រាក់ឲ្យអ្នកលក់"។ ករណីនេះ ប្រសិនបើភាគីអ្នកលក់បានផ្ទេរកម្មសិទ្ធិ និងសិទ្ធិផ្សេងដែលមានលើវត្ថុហើយនោះ ភាគីអ្នកទិញត្រូវប្រគល់ប្រាក់ដែលជាតម្លៃតបមកឲ្យភាគីអ្នកលក់វិញ ផ្ទុយទៅវិញ ប្រសិនបើភាគីអ្នកទិញមិនបានប្រគល់ប្រាក់មកឲ្យភាគីអ្នកលក់ទេនោះ ភាគីអ្នកលក់មានសិទ្ធិទាមទារឲ្យបង់តម្លៃតបនៃវត្ថុបានដោយផ្អែកលើសិទ្ធិលើបំណុលដោយផ្អែកលើកិច្ចសន្យាលក់ ទិញនោះ។ ករណីនេះអនុវត្តដូចគ្នាផងដែរប្រសិនបើភាគីអ្នកលក់មិនអនុវត្តករណីកិច្ចរបស់ខ្លួន។

ក្នុងករណីដែលដើមចោទធ្វើការទាមទារ ហើយចុងចម្លើយទទួលស្គាល់ការទាមទារនោះ តុលាការនឹងកត់ត្រានៅក្នុងកំណត់ហេតុស្តីពីការសះជា។ កំណត់ហេតុស្តីពីការសះជានេះមានអានុភាពដូចគ្នាទៅនឹងសាលក្រមស្ថាពរ[40]។

កំណត់ហេតុស្តីពីការសះជា សំដៅលើលិខិតដែលកត់ត្រាអំពីលទ្ធផលនៃការផ្សះផ្សាដែលភាគីបានព្រមព្រៀងគ្នា និងនាំឲ្យរឿងក្តីត្រូវបានបញ្ចប់ ហើយវាមានអានុភាពដូចគ្នានឹងសាលក្រមស្ថាពរដែរ។ ករណីដែលដើមចោទទាមទារ ហើយចុងចម្លើយមិនទទួលស្គាល់ការទាមទារនោះ តុលាការនឹងឲ្យដើមចោទធ្វើការអះអាងអំពីអង្គហេតុដែលជាមូលហេតុនៃការទាមទារ បន្ទាប់មកភាគីទាំងសងខាងត្រូវទទួលបន្ទុកក្នុងការស្វែងរកភស្តុតាងដើម្បីបញ្ជាក់អំពីអត្ថិភាព ឬ នត្ថិភាព ឬ ទំនាក់ទំនងគតិយុត្តផ្សេងទៀតចំពោះអង្គហេតុដែលបានលើកឡើង។

ការទទួលស្គាល់ ឬ មិនទទួលស្គាល់នូវអង្គហេតុរបស់ចុងចម្លើយ អាចធ្វើឡើងបានតាម ៤ របៀបៈ

ការទទួលស្គាល់នូវការទាមទារ គឺជាការបង្ហាញឆន្ទៈទទួលស្គាល់ទាំងស្រុងនូវការទាមទារតាមផ្លូវបណ្តឹងដោយចុងចម្លើយ។ តាមរយៈការទទួលស្គាល់នេះ បណ្តឹងអាចត្រូវបានបញ្ចប់ហើយត្រូវសរសេរក្នុងកំណត់ហេតុថា បានទទួលស្គាល់នូវការទាមទារ ហើយកំណត់ហេតុនេះមានអានុភាពដូចគ្នានឹងសាលក្រមស្ថាពរ[41] ។

### ក. ការសារភាព

ការសារភាព[42] គឺជាការបង្ហាញឆន្ទៈទទួលស្គាល់នូវអង្គហេតុចម្បងដែលអះអាងដោយភាគីម្ខាងទៀត។ តាមរយៈការទទួលស្គាលនេះ ភាគីមិនចាំបាច់ធ្វើការបញ្ជាក់ភស្តុតាងអំពីអង្គហេតុចម្បងនោះទេ ប៉ុន្តែក៏ពុំមានអានុភាពបញ្ចប់បណ្តឹងនោះដែរ។ ការសារភាពតាមផ្លូវតុលាការមានអានុភាពពីរ គឺអានុភាពចំពោះតុលាការ និងអានុភាពចំពោះភាគី។

១. អានុភាពចំពោះតុលាការៈ ការសារភាពតាមផ្លូវតុលាការ មានអានុភាពចងតុលាការ ហើយធ្វើឲ្យតុលាការបាត់បង់សិទ្ធិវិនិច្ឆ័យដោយផ្អែកលើភស្តុតាង។

២. អានុភាពចំពោះភាគីៈ ការសារភាពតាមផ្លូវតុលាការ មានអានុភាពចងភាគីដែលបានសារភាព ពោលគឺមិនអានុញ្ញាតឲ្យភាគីនោះដកការសារភាព ហើយធ្វើការអះអាងផ្ទុយពីការសារភាពលើកមុនបានឡើយ។ ការហាមដូចនេះធ្វើឡើងដើម្បីជៀសវាងនូវភាពច្របូកច្របល់ក្នុងនីតិវិធីដែល

[40] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ២២២

[41] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ២២២

[42] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១២៣ កថាខណ្ឌទី២

នាំឲ្យមានការយឺតយ៉ាវដល់ការវិនិច្ឆ័យបណ្តឹង និងធ្វើឲ្យមានការខូចខាតដល់ផលប្រយោជន៍របស់ភាគីម្ខាងទៀត។ ប៉ុន្តែទោះបីជាយ៉ាងនេះក្តី ក៏មានករណីពិសេសដែលច្បាប់ទទួលស្គាល់ឲ្យដកការសារភាពវិញបាន ក្នុងគោលបំណងការពារនូវសមធម៌ និងសច្ចៈភាព គឺអនុញ្ញាតតែការដកការសារភាពទាំងឡាយដែលមិនមានការតវ៉ាពីភាគីម្ខាងទៀត ការសារភាពដោយ ការភ័ន្តច្រឡំ ដែលផ្ទុយនឹងការពិត ឬ ការសារភាពបណ្តាលមកពីសកម្មភាពបទល្មើសរបស់ជនដទៃ[43]។

### ខ. ការមិនទទួលស្គាល់ ឬ បដិសេធ

ការមិនទទួលស្គាល់ ឬ ការបដិសេធ[44] គឺជាការបង្ហាញឆន្ទៈ មិនទទួលស្គាល់ ឬ បដិសេធអង្គហេតុ ឬ ភស្តុតាងដែលអះអាងដោយភាគីម្ខាងទៀត។ ការមិនទទួលស្គាល់ ឬ បដិសេធនេះ ភាគីត្រូវធ្វើការបញ្ជាក់ភស្តុតាង (លើកលែងអង្គហេតុជាក់ស្តែង)។

### គ. មិនដឹង

ពាក្យថាមិនដឹង[45] គឺជាការបង្ហាញឆន្ទៈដោយប្រាប់ថា ខ្លួនមិនបានដឹងអំពីអង្គហេតុដែលអះអាងដោយភាគីម្ខាងទៀត។ ភាគីដែលបានបង្ហាញឆន្ទៈមិនដឹង ត្រូវធ្វើការបញ្ជាក់ដោយភស្តុតាង។

### ឃ. នៅស្ងៀមមិនបង្ហាញឆន្ទៈ

ការនៅស្ងៀមមិនបង្ហាញឆន្ទៈ[46] ក្នុងករណីដែលភាគីមិនបានបង្ហាញច្បាស់លាស់នូវឆន្ទៈតវ៉ាអំពីអង្គហេតុដែលអះអាងដោយភាគីម្ខាងទៀតក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ទេ ភាគីនោះត្រូវចាត់ទុកថា បានសារភាពអំពីអង្គហេតុនោះ។ ភាគីមិនចាំបាច់ធ្វើការបញ្ជាក់ដោយភស្តុតាងទេ ប៉ុន្តែ បើសិនមើលទៅតាមសភាពនៃការជំនុំជម្រះទៅយើងឃើញថា អង្គហេតុនោះមានវិវាទចាំបាច់ត្រូវធ្វើការបញ្ជាក់ដោយភស្តុតាង។

ទោះបីជាមានការទទួលស្គាល់នូវមូលហេតុនៃការទាមទារទាំងអស់ក៏ដោយ ប៉ុន្តែបើមានការអះអាងដែលអាចបដិសេធនូវកំណើតសិទ្ធិ គឺជាការតវ៉ា។

ការតវ៉ា គឺជាអង្គហេតុដែលអះអាងដោយចុងចម្លើយដើម្បីបង្កើតជាឧបសគ្គនៃការកកើតនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត ឬ រំលត់សិទ្ធិដែលកើតឡើងម្តងហើយ ឬ រាំងនូវការអនុវត្តសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត ដែលអះអាងដោយដើមចោទ។

ឧទាហរណ៍៖ ខ្ញុំបានទិញមែន ប៉ុន្តែត្រូវបានគេបោក ដូច្នេះ សូមលុបចោលកិច្ចសន្យាវិញ។ ការអះអាងបែបនេះជាការតវ៉ា។

---

[43] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១២៣ កថាខណ្ឌទី ៣

[44] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១២៣ កថាខណ្ឌទី១

[45] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៩៦ កថាខណ្ឌទី២

[46] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៩៦ កថាខណ្ឌទី១

ការតវ៉ា ត្រូវបានបែងចែកជា បួន ប្រភេទ៖

១. ការតវ៉ាអំពីកំណើតនៃសិទ្ធិ

២. ការតវ៉ាអំពីឧបសគ្គនៃសិទ្ធិ

ឧទាហរណ៍៖ ការលុបចោលដោយសារការភ័ន្តច្រឡំ (មាត្រា ៣៤៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី)។

៣. ការតវ៉ាអំពីការរលត់នៃសិទ្ធិ

ឧទាហរណ៍៖ ការសង (មាត្រា ៤៣៣ ចំណុច ក នៃក្រមរដ្ឋប្បវេណី) អាជ្ញាយុកាលនៃការរំលត់សិទ្ធិ (មាត្រា ៤៨០ ទៅ នៃក្រមរដ្ឋប្បវេណី)។

៤. ការតវ៉ាអំពីការរារាំងសិទ្ធិ

ឧទាហរណ៍៖ ការតវ៉ាឲ្យអនុវត្តព្រមគ្នា(មាត្រា ៥៥១ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី)។

## ២.៣ ការអះអាង

### ២.៣.១. គោលគំនិតនៃការអះអាង

ការអះអាងរបស់ភាគី គឺជាសកម្មភាពបង្ហាញចំពោះតុលាការនូវអង្គហេតុដែលជាមូលដ្ឋាននៃអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលទាមទារតាមផ្លូវបណ្តឹង។ ជាគោលការណ៍ ការអះអាងរបស់ភាគី គេមិនចាត់ទុកថាជា ភស្តុតាងនោះទេ។

ការអះអាងរបស់ភាគីចុងចម្លើយ គឺជាការលើកឡើងនូវបញ្ហាតាមផ្លូវច្បាប់បញ្ជាក់អំពីនត្ថិភាពនៃសិទ្ធិ។ ដូចនេះ ដើម្បីប្រឆាំងតបនឹងដើមចោទ ចុងចម្លើយអាចមិនទទួលស្គាល់អង្គហេតុដែលជាមូលហេតុនៃការទាមទារ ឬក៏អាចអះអាងតវ៉ាចំពោះដើមចោទបាន។

ចំណែកឯការអះអាងរបស់ភាគីដើមចោទវិញ គឺជាការលើកឡើងនូវបញ្ហាតាមផ្លូវច្បាប់ដើម្បីបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិ។

### ២.៣.២. មូលហេតុដែលអនុញ្ញាតឲ្យធ្វើការអះអាង

មុននឹងឈានដល់ការសម្រេចសេចក្តីតុលាការ ត្រូវពិចារណាទៅលើអង្គហេតុដែលគូភាគីបានលើកឡើង តាមរយៈការបង្ហាញភស្តុតាងជាមួយនឹងការអះអាងដែលគូភាគីត្រូវធ្វើការបញ្ជាក់អំពីអត្ថិភាព ឬ នត្ថិភាព ឬ ទំនាក់ទំនងគតិយុត្តនៃសិទ្ធិ។ តុលាការអាចសម្រេចទៅលើចំណុចណាដែលគូភាគីបានទាមទារប៉ុណ្ណោះ ម្យ៉ាងវិញទៀត បើទោះបីជាមានអង្គហេតុជាក់ស្តែងដែលមានផលប្រយោជន៍សម្រាប់ភាគីក៏ដោយ តែបើភាគីមិនបានអះអាងទេ តុលាការមិនអាចពិនិត្យនូវអង្គហេតុ

នោះដើម្បីចេញសាលក្រមបានឡើយ។ ការណ៍នេះហើយ ធ្វើឲ្យភាគីរងនូវការខូចប្រយោជន៍ដោយសារតែតុលាការមិនអាចទទួលស្គាល់នូវអានុភាពគតិយុត្ត ដែលមានប្រយោជន៍សម្រាប់ភាគីនោះ (ដូចជាការកកើត ឬ ការរលត់នៃសិទ្ធិជាអាទិ៍)។ ដោយហេតុនេះហើយ ភាគីត្រូវទទួលខុសត្រូវធ្វើការអះអាងនូវអង្គហេតុដែលមានផលប្រយោជន៍ដល់ខ្លួន ប្រសិនខ្លួនចង់ឈ្នះក្តី ហើយការទទួលខុសត្រូវនេះ គេហៅថា "ការទទួលខុសត្រូវក្នុងការអះអាង"។

ឧទាហរណ៍៖ បើទោះបីជាមានអង្គហេតុថា ចុងចម្លើយបានសងប្រាក់កម្ចីនោះរួចហើយក៏ដោយ តែបើចុងចម្លើយមិនបានអះអាងទេ តុលាការមិនអាចយកអង្គហេតុនោះមកពិចារណាបានឡើយ ដោយហេតុនេះតុលាការមិនអាចទទួលស្គាល់ថា កាតព្វកិច្ចរបស់ចុងចម្លើយបានរលត់ដោយការសងនោះបានទេ។ ទោះបីជាតាមរយៈចម្លើយរបស់សាក្សីធ្វើឲ្យតុលាការគិតថា ចុងចម្លើយបានសងបំណុលនោះរួចក៏ដោយ តែប្រសិនបើភាគីមិនបានអះអាងអំពីអង្គហេតុនេះទេ តុលាការមិនអាចយកការគិតឃើញរបស់ខ្លួននេះមកធ្វើជាមូលដ្ឋានក្នុងការសម្រេចសេចក្តីលើអត្ថិភាព ឬ នត្ថិភាព ឬទំនាក់ទំនងគតិយុត្តដែលអះអាងដោយដើមចោទបានឡើយ ក្នុងករណីនេះតុលាការត្រូវអនុវត្តសិទ្ធិបំភ្លឺ ។

ជាងនេះទៅទៀត ដើម្បីឲ្យតុលាការទទួលស្គាល់នូវការទាមទារតាមរយៈការអះអាង ភាគីត្រូវលើកឡើងអំពីអង្គហេតុចម្បង ជាពិសេស គឺហេតុដែលជាមូលហេតុនៃការទាមទារ ដែលជាប្រភេទនៃអង្គហេតុចម្បង។ ក្នុងករណីដែលដើមចោទមិនអាចអះអាងអង្គហេតុអំពីកំណើតនៃសិទ្ធិបានគ្រប់គ្រាន់នោះទេ តុលាការនឹងច្រានចោលការទាមទាររបស់ដើមចោទ។ ក្នុងករណីដែលចុងចម្លើយមិនយល់ព្រមនឹងការទាមទាររបស់ដើមចោទ ចុងចម្លើយអាចមិនទទួលស្គាល់អង្គហេតុដែលជាមូលហេតុនៃការទាមទាររបស់ដើមចោទ ឬក៏អាចលើកឡើងនូវអង្គហេតុតវ៉ាបាន។ អង្គហេតុតវ៉ាជាប្រភេទនៃអង្គហេតុចម្បង រួមមាន: អង្គហេតុរារាំងការកកើតសិទ្ធិ អង្គហេតុរលត់សិទ្ធិ និង អង្គហេតុទប់ស្កាត់ការប្រើប្រាស់សិទ្ធិ។

### ២.៣.៣. ដំណាក់កាលនៃការអះអាង

នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី គេទទួលស្គាល់គោលការណ៍នៃការទាញហេតុផលដោយផ្ទាល់មាត់ដើម្បីធ្វើជាមូលដ្ឋានសម្រប់ឲ្យតុលាការចេញសេចក្តីសម្រេចជាសាលក្រម។ ដូចនេះ អង្គហេតុចម្បងដែលអាចធ្វើជាមូលដ្ឋាននៃសាលក្រម គឺជាអង្គហេតុដែលភាគីអះអាងនៅក្នុងនីតិវិធីទាញ

ហេតុផល ឬ នីតិវិធីត្រៀមតែប៉ុណ្ណោះ ហើយប្រសិនបើភាគីមិនអះអាងអង្គហេតុនោះទេ តុលាការមិនអាចយកអង្គហេតុនោះមកធ្វើជាមូលដ្ឋានដើម្បីចេញសាលក្រមបានឡើយ។

### ២.៤ ការបញ្ជាក់ (ភស្តុតាង និង អង្គហេតុ)

#### ២.៤.១. អត្ថន័យ និងភាពចាំបាច់ក្នុងការទទួលខុសត្រូវក្នុងការបញ្ជាក់

គ្រប់អង្គហេតុ និងភស្តុតាងសុទ្ធតែមានអ្នកទទួលខុសត្រូវក្នុងការបញ្ជាក់។ មានន័យថា ភាគីត្រូវធ្វើការបញ្ជាក់អង្គហេតុដោយភស្តុតាង ឬ បង្ហាញថា ភស្តុតាងមួយជាភស្តុតាងពិតប្រាកដ ភាគីត្រូវបញ្ជាក់បង្ហាញអំពីអង្គហេតុពិតណាមួយដែលមានភាពទាក់ទងជាមួយនឹងភស្តុតាងនោះ។

ឧទាហរណ៍៖ ក្នុងករណីដែលដើមចោទទាមទារឲ្យចុងចម្លើយសងប្រាក់កម្ចីផ្អែកលើកិច្ចសន្យាខ្ចីបរិភោគ ដើមចោទត្រូវអះអាងអំពីការព្រមព្រៀងសង ការប្រគល់ប្រាក់ដោយផ្អែកលើការព្រមព្រៀងនោះ និងពេលកំណត់សងបានមកដល់។ ប្រសិនបើដើមចោទមិនអាចបញ្ជាក់នូវអង្គហេតុណាមួយក្នុងចំណោមអង្គហេតុទាំងបីខាងលើនេះ ដោយបង្ហាញអំពីភស្តុតាងមួយចំនួនដូចជា លិខិតបង្កើតកិច្ចសន្យាខ្ចីបរិភោគ ឬ សាក្សីដែលបានចូលរួមក្នុងការបង្កើតកិច្ចសន្យានោះទេ តុលាការមិនអាចទទួលស្គាល់នូវការកើតឡើងនូវសិទ្ធិទាមទារឲ្យសងប្រាក់កម្ចីនោះបានទេ។

ហេតុដូចនេះហើយ ភាគីដែលបានអះអាងអំពីអត្ថិភាព ឬ នត្ថិភាពនៃអង្គហេតុដែលជាការកកើតឡើងនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត ចាំបាច់ត្រូវធ្វើការបញ្ជាក់អង្គហេតុនោះដោយភស្តុតាងដើម្បីធ្វើឲ្យតុលាការអាចយល់ដឹងអំពីអត្ថិភាព ឬ នត្ថិភាពនៃអង្គហេតុ ដើម្បីឈានទៅដល់ការចេញនូវសេចក្តីមសម្រេច ក្នុងការបញ្ចប់នូវវិវាទដែលបានកើតឡើងនោះ។

#### ២.៤.២. វិធីបញ្ជាក់ភស្តុតាងនៃអង្គហេតុ

ដើម្បីធ្វើការបញ្ជាក់ភស្តុតាងនៃអង្គហេតុ គេមានវិធីពីរយ៉ាង។ វិធីទីមួយ គឺការទទួលស្គាល់ដោយផ្ទាល់នូវអង្គហេតុ វិធីទីពីរ គឺការទទួលស្គាល់នូវអង្គហេតុប្រយោលតាមរយៈភស្តុតាងប្រយោល។ បើសិនជាមានកង្វះខាតនូវភស្តុតាងផ្ទាល់ដើម្បីបញ្ជាក់អង្គហេតុចម្បង ដើមចោទគប្បីសរសេរក្នុងពាក្យបណ្តឹងនូវអង្គហេតុប្រយោលឲ្យបានច្រើន។ ផ្ទុយទៅវិញ ប្រសិនបើមានភស្តុតាងច្បាស់លាស់ហើយ គេមិនចាំបាច់សរសេរអង្គហេតុប្រោលក៏បានដែរ។

ឧទាហរណ៍៖ ដើម្បីបញ្ជាក់ពីអង្គហេតុចម្បង " X បានឲ្យប្រាក់ Y ខ្ចីចំនួន ១ ០០០ ដុល្លារ " ដើមចោទអាចអះអាងនូវអង្គហេតុប្រយោល ដូចតទៅ៖ "X បានមកដកប្រាក់នៅធនាគារចំនួន ១ ០០០ ដុល្លារ មុនពេលឲ្យប្រាក់ទៅ Y ខ្ចី ហើយ Y បានទិញម៉ូតូមួយគ្រឿងក្នុងតម្លៃប្រហែល ១ ០០០ ដុល្លារ ក្រោយពេលឲ្យខ្ចីប្រាក់។

ការបញ្ជាក់ភស្តុតាង ត្រូវធ្វើនៅដំណាក់កាលទាញហេតុផលដោយផ្ទាល់មាត់តាមរយៈការស្នើរសុំរបស់ភាគី[47] បន្ទាប់មក តុលាការធ្វើការសម្រេចថាទទួលយកសំណើរ ឬ មិនទទួលយក ឬ ករណីប្រសិនបើមានភាពចាំបាច់ តុលាការអាចធ្វើការពិនិត្យភស្តុតាងតាមឆន្ទានុសិទ្ធិរបស់ខ្លួន[48]។

### ២.៤.៣. ការបែងចែកការទទួលខុសត្រូវក្នុងការបញ្ជាក់

គោលការណ៍នៃក្រមនីតិរដ្ឋប្បវេណីបានចែងថា អ្នកដែលទទួលផលប្រយោជន៍ពីការកកើតឡើងនូវទំនាក់ទំនងគតិយុត្តមានករណីកិច្ចត្រូវទទួលខុសត្រូវក្នុងការបញ្ជាក់។ ចំពោះអង្គហេតុដែលជាមូលហេតុនៃការកើតឡើងនូវសិទ្ធិ ភាគីដែលបានលើកឡើងពីអង្គហេតុនេះ ជាអ្នកទទួលខុសត្រូវក្នុងការបញ្ជាក់។ ក៏ដូចគ្នាដែរ ចំពោះអង្គហេតុរារាំង ឬ រំលត់សិទ្ធិ ឬ ទប់ស្កាត់ការប្រើប្រាស់សិទ្ធិ ភាគីដែលបានលើកឡើងនូវអង្គហេតុទាំងនេះ ត្រូវទទួលខុសត្រូវក្នុងការបញ្ជាក់។

ដើម្បីចេញសាលក្រម តុលាការត្រូវពិចារណាទៅលើអង្គហេតុដែលកើតមានដើម្បីផ្ទៀងផ្ទាត់នឹងច្បាប់។ អង្គហេតុត្រូវបានទទួលស្គាល់ដោយតុលាការ តាមរយៈការសារភាព ឬ តុលាការអាចទទួលស្គាល់អង្គហេតុដែលមានវិវាទតាមរយៈភស្តុតាង ដែលភាគីទទួលខុសត្រូវក្នុងការបញ្ជាក់តាមរយៈការស្នើរសុំឲ្យពិនិត្យ។ បើទោះបីជា តុលាការពិនិត្យមើលភស្តុតាងរួចហើយក៏ដោយ បើសិនជាតុលាការមិនអាចយល់ដឹងបានថា អង្គហេតុនោះពិតជាមាននោះទេ តុលាការនឹងសន្មត់ថាអង្គហេតុនោះអត់មាន។ ដូច្នេះ វាមានសារសំខាន់ណាស់ដែលភាគីត្រូវធ្វើការបញ្ជាក់អង្គហេតុឲ្យកាន់តែច្បាស់ថែមទៀត ដើម្បីអាចឲ្យតុលាការទទួលស្គាល់អង្គហេតុ និងអាចសម្រេចតាមការទាមទាររបស់ភាគីណាមួយនោះ។

[47] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១២៥

[48] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១២៤ កថាខណ្ឌទី២

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានសិក្សាស្រាវជ្រាវ និងបកស្រាយលើប្រធានបទស្តីពី "**អង្គហេតុចម្បង និងការសរសេរពាក្យបណ្តឹង**" អស់រយៈពេលមួយរយៈកន្លងមក យើងអាចធ្វើការសន្និដ្ឋានដូចតទៅៈ ជាការពិតណាស់ ដើម្បីរៀបចំនូវចំណុចវិវាទប្រព្រឹត្តទៅដោយរលូន ភាគីក្នុងរឿងក្តីរដ្ឋប្បវេណីត្រូវស្វែងយល់ជាចាំបាច់អំពីអង្គហេតុវិវាទជាមុនសិន ដើម្បីងាយស្រួលនឹងរៀបចំសរសេរក្នុងពាក្យបណ្តឹងដាក់ជូនតុលាការ។ ប្រសិនបើយើងធ្វើការបែងចែងឲ្យបានច្បាស់រវាងប្រភេទនៃអង្គហេតុជាមួយនឹងប្រភេទបណ្តឹងដែលមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណី នោះយើងនឹងងាយស្រួលក្នុងការសរសេរពាក្យបណ្តឹងបានច្បាស់លាស់ ចំនូវចំណុចវិវាទ និងបង្កភាពងាយស្រួលដល់តុលាការដំណើរការរឿងក្តី និងឈានទៅដល់ការសម្រេចសេចក្តី។

តាមរយៈប្រធានបទខាងលើ អង្គហេតុចម្បងត្រូវបានគេចាត់ទុកជាអង្គហេតុមួយដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការបញ្ជាក់អំពី អត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិដែលគូភាគីបានអះអាងនៅក្នុងការថ្លែងការណ៍របស់ខ្លួន។ ដើម្បីអាចឲ្យតុលាការទទួលស្គាល់នូវអង្គហេតុដែលភាគីបានលើកឡើង តុលាការត្រូវធ្វើការពិចារណាដោយផ្អែកទៅលើភស្តុតាងនៃអង្គហេតុនោះ ថាតើអង្គហេតុនោះបានបញ្ជាក់អំពីសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលភាគីបានអះអាងដែរឬទេ។ អង្គហេតុចម្បងត្រូវបានបែងចែកជា ៤ (បួន) ប្រភេទ ទៅតាមស្តង់ដារនៃបញ្ញត្តិច្បាប់សារធាតុ ទៅតាមមុខងារនៃអានុភាពគតិយុត្ត ដូចជាៈ អង្គហេតុនៃកំណើតសិទ្ធិ (បទបញ្ញត្តិចែងអំពីលក្ខខណ្ឌនៃកំណើតសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត) អង្គហេតុនៃឧបសគ្គសិទ្ធិ (បទបញ្ញត្តិចែងអំពីឧបសគ្គនៃសិទ្ធិ) អង្គហេតុរំលត់សិទ្ធិ (បទបញ្ញត្តិចែងអំពីលក្ខខណ្ឌនៃការរលត់សិទ្ធិដែលបានកើតឡើង) និងអង្គហេតុរាំងសិទ្ធិ (បទបញ្ញត្តិចែងអំពីការរារាំងការអនុវត្តសិទ្ធិមួយរយៈពេល)។ បន្ទាប់ពីបានស្វែងយល់អំពីអង្គហេតុចម្បងរួចហើយ ភាគីត្រូវយកចិត្តទុកដាក់ទៅលើទម្រង់បែបបទនៃការសរសេរពាក្យបណ្តឹងវិញម្តង។ ទម្រង់នៃពាក្យបណ្តឹងមានចែងក្នុងមាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ នៅក្នុងពាក្យបណ្តឹង ភាគី ឬ អ្នកតំណាងដោយអាណត្តិ ត្រូវសរសេរឲ្យបានច្បាស់លាស់នូវអត្តសញ្ញាណ និងអាសយដ្ឋានរបស់គូភាគី (ទាំងភាគីដើមចោទ និងចុងចម្លើយ) និងអត្តសញ្ញាណ អាសយដ្ឋានរបស់អ្នកតំណាង (បើមាន)។ ភាគីត្រូវសរសេរអំពីចំណុចដែលខ្លួនចង់ទាមទារឲ្យតុលាការចេញ មានន័យថាខ្លឹមសារនៃសាលក្រមដែលទាមទារឲ្យតុលាការចេញឲ្យបានច្បាស់លាស់ ពីព្រោះ តុលាការចេញសេចក្តី

សម្រេចដោយផ្អែកទៅលើការទាមទាររបស់ភាគីប៉ុណ្ណោះ វៀលែងតែ មានករណីពិសេសដែលចែងដោយក្រមនីតិវិធីរដ្ឋប្បវេណី ឬ បទបញ្ញត្តិផ្សេងទៀត។ ហើយចំណុចមួយទៀតដែលភាគីត្រូវសរសេរជាចាំបាច់ផងដែរ គឺអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ ពីព្រោះវាជាអង្គហេតុមូលដ្ឋាន ឬជាសំអាងសម្រាប់ធ្វើការទាមទារ។ ចំណែកឯ ចំណុចដែលគួគប្បីសរសេរផ្សេងទៀតក្នុងពាក្យបណ្តឹងមាន (១) អង្គហេតុដែលជាមូលហេតុនៃការទាមទារ (អង្គហេតុចម្បង) ដែលជាប្រភេទអង្គហេតុអះអាងដោយដើមចោទដើម្បីឲ្យកើតឡើងនូវសិទ្ធិទាមទារ។ (២) អង្គហេតុសំខាន់ៗដែលទាក់ទងជាមួយនឹងអង្គហេតុដែលជាមូលហេតុនៃការទាមទារ ជាប្រភេទអង្គហេតុប្រយោលមួយដែលគេប្រើនៅពេលដែលពុំមានភស្តុតាងដោយផ្ទាល់គ្រប់គ្រាន់ដើម្បីបញ្ជាក់អំពីអង្គហេតុដែលជាមូលហេតុនៃការទាមទារ។ (៣) ចំណុចមួយទៀតដែលគប្បីដាក់បញ្ចូលក្នុងពាក្យបណ្តឹងផងដែរនោះ គឺ ភស្តុតាង។ សូមបញ្ជាក់ថា ចំណុច (១) (២) និង (៣) ខាងលើនេះ បើទោះបី ភាគីមិនបានសរសេរ ឬ ដាក់បញ្ចូលក្នុងពាក្យបណ្តឹងក៏ដោយ ក៏មិនមែនជាមូលហេតុដែលតុលាការលើកបណ្តឹងចោល ឬ បង្គាប់ឲ្យកែតម្រូវដែរ។ ប៉ុន្តែដើម្បីឲ្យតុលាការងាយស្រួលស្វែងយល់ពីបណ្តឹងឲ្យបានច្បាស់លាស់ ភាគីគប្បីសរសេរ និងដាក់បញ្ចូលឲ្យហើយ ចៀសវៀង ការបង្អាក់ដំណើរការនៃនីតិវិធីប្រព្រឹត្តទៅមិនបានរលូន។

សរុបសេចក្តីមក ការស្វែងយល់អំពីអង្គហេតុ គឺជាការចាំបាច់បំផុតមុននឹងឈានទៅដល់ការសរសេរពាក្យបណ្តឹង ដោយហេតុថា អង្គហេតុក្នុងក្តីរដ្ឋប្បវេណីមានច្រើនប្រភេទដូចដែលបានរៀបរាប់ខាងលើ។ នៅក្នុងការអនុវត្តជាក់ស្តែង យើងសង្កេតឃើញថា មានអ្នកប្រកបវិជ្ជាជីវៈ និងអ្នកអនុវត្តច្បាប់មួយចំនួន ហាក់បីដូចជាមិនសូវយកចិត្តទុកដាក់ និងធ្វើការស្វែងយល់អំពីប្រភេទនៃអង្គហេតុ និងទម្រង់នៃពាក្យបណ្តឹងដូចដែលមានបញ្ញត្តិក្នុងក្រមនីតិវិធីរដ្ឋប្បវេណីជាធរមាននោះទេ។ ដោយករណីខ្លះ ភាគីមិនបានបញ្ជាក់ទាក់ទងទៅនឹងអត្តសញ្ញាណ ឬ ខ្លឹមសារនៃសាលក្រមដែលទាមទារឲ្យតុលាការចេញ ដែលមិនមានផលប្រយោជន៍នៃបណ្តឹង។ កត្តាទាំងអស់នេះហើយ ដែលធ្វើឲ្យស្ថាប័នតុលាការមិនអាចដំណើរការនីតិវិធីបានដោយរលូន ហើយជាហេតុដែលតុលាការបង្គាប់ឲ្យភាគីធ្វើការកែតម្រូវ ឬ អាចលើកបណ្តឹងចោល។

# ឯកសារយោង

## ច្បាប់ និង បទបញ្ញត្តិផ្សេងៗ


1. ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ ២០០៦ ។
2. ក្រមរដ្ឋប្បវេណី, នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ ២០០៧ ។


## សៀវភៅ និង ឯកសារផ្សេងៗ


3. សេចក្តីពន្យល់ អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគទី១ ស្តីពី *"នីតិវិធីបណ្តឹង"*។
4. ឯកសារសិក្ខាសាលាស្តីពី *"អង្គហេតុចម្បង និង ការសរសេរពាក្យបណ្តឹង"* រៀបចំដោយ មេធាវី **រស់ អម្រិត** មេធាវី **មាស ស៊ីថន** និង មេធាវី **សួង សុភា** កាលបរិច្ឆេទ ថ្ងៃទី២០ ខែសីហា ឆ្នាំ ២០១៥ ។
5. ឯកសារសិក្ខាសាលាស្តីពី *"អង្គហេតុចម្បងដែលជាធាតុផ្សំ"* របស់វគ្គបណ្តុះបណ្តាលជំនួយក្នុងការផ្សព្វផ្សាយក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី លើកទី៤ ថ្ងៃទី១២ ខែមិថុនា ឆ្នាំ ២០១៤ ដោយមេធាវី Hiroshi Hasegawa ។
6. ឯកសារសិក្ខាសាលាស្តីពី *"ការសរសេរពាក្យបណ្តឹង និង ឯកសារត្រៀម"* ឧទ្ទេសនាមដោយ លោកមេធាវី **អ៊ីវ ប៉ូលី** និងលោកស្រីមេធាវី **ទេព បូផល** នៅគណៈមេធាវី កាលពីថ្ងៃទី០៣ ខែមីនា ឆ្នាំ ២០១៦ ។
7. សៀវភៅមេរៀនស្តីពី *"មូលដ្ឋាននៃអង្គហេតុចម្បង"* របស់ក្រុមការងារកិច្ចការរដ្ឋប្បវេណីនៃគណៈមេធាវី ឆ្នាំ ២០១០។
8. សៀវភៅស្តីពី *"ការពន្យល់អំពីនីតិវិធីជំនុំជម្រះលើកទី១"* ដែលបានបោះពុម្ពជាលើកទី២ ខែវិច្ឆិកា ឆ្នាំ ២០០៩ ។